ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ រាធរ និងឯកសារពាក់ព័ន្ធ

ឈ្មោះសហគមន៍នេសាទ : រាធរ
ភូមិ : ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ
ឃុំ : រាធរ
ស្រុក : ព្រះស្តេច
ខេត្ត : ព្រៃវែង

# បញ្ជីអត្ថបទ


១. កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

២. ផែនទីកន្លែងនេសាទសហគមន៍

៣. បញ្ជីឈ្មោះសមាជិកនិងគណៈកម្មការសហគមន៍នេសាទ និងរចនាសម្ព័ន្ធ

៤. លក្ខន្តិកៈសហគមន៍នេសាទ

៥. បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

៦. សេចក្តីថ្លែងការណ៍នៃការបង្កើតសហគមន៍នេសាទ

៧. ឯកសារផ្សេងៗ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : រាធរ |
| ភូមិ | : ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ |
| ឃុំ | : រាធរ |
| ស្រុក | : ព្រះស្ដេច |
| ខេត្ត | : ព្រៃវែង |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : រាធរ |
| ភូមិ | : ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ |
| ឃុំ | : រាធរ |
| ស្រុក | : ព្រះស្ដេច |
| ខេត្ត | : ព្រៃវែង |

# កិច្ចព្រមព្រៀង
# កន្លែងនេសាទសហគមន៍

## រវាង

នាយខណ្ឌរដ្ឋបាលជលផលព្រៃវែង ជាតំណាងស្របច្បាប់ នៃរដ្ឋបាលជលផល មានអាសយដ្ឋាន នៅភូមិ៤ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ទូរស័ព្ទលេខ: ០៨៨.៨៧២.៧៧៦៦ ហៅថា " ភាគី **ក** "។

## និង

ប្រធានគណៈកម្មការសហគមន៍នេសាទ**រាធរ** ជាតំណាងស្របច្បាប់ឱ្យសហគមន៍នេសាទ ដែលមានអាសយដ្ឋានស្ថិតនៅ: ភូមិឈ្នះជ័យលើ ឃុំរាធរ ស្រុកព្រះស្តេច ខេត្តព្រៃវែង ទូរស័ព្ទលេខ:០៩៧ ៩៨៣ ៩៩០៤ ហៅថា" ភាគី **ខ** "

**ភាគីទាំងពីរបានឯកភាពគ្នា ចុះកិច្ចព្រមព្រៀងតាមលក្ខខណ្ឌដូចខាងក្រោម៖**

**ប្រការ ១.-**

ភាគី **ក** ប្រគល់ដែននេសាទ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ឱ្យភាគី **ខ** ធ្វើការគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលរយៈពេល៣ឆ្នាំ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ រហូតដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ ដោយធានានូវចីរភាពតាមរយៈការរៀបចំសហគមន៍នេសាទ ។

**ប្រការ ២.-**

ដែននេសាទនេះ មានឈ្មោះថា កន្លែងនេសាទសហគមន៍**រាធរ** ដែលលាតសន្ធឹងនៅក្នុង៖

- ភូមិឈ្នះជ័យលើ ឃុំរាធរ ស្រុកព្រះស្តេច ខេត្តព្រៃវែង
- ភូមិឈ្នះជ័យក្រោម ឃុំរាធរ ស្រុកព្រះស្តេច ខេត្តព្រៃវែង
- ភូមិតាម៉ៅ ឃុំរាធរ ស្រុកព្រះស្តេច ខេត្តព្រៃវែង

មាននិយាមកាដូចខាងក្រោម៖

និយាមកាកន្លែងនេសាទសហគមន៍

| id | x | y | |
|---|---|---|---|
| 1 | 537545 | 1233438 | បឹងវាលប្រា |
| 2 | 537529 | 1231002 | អូរអ្នកតាស្នាយ |
| 3 | 534769 | 1228303 | ឈូងពោធិ៍ |
| 4 | 534198 | 1228210 | កំពង់ដរដីក្រហម |
| 5 | 533905 | 1229367 | កែងព្រែកអាផាយ |
| 6 | 534214 | 1229675 | កែងឈ្នះជ័យក្រោម |
| 7 | 535093 | 1229645 | កែងឈ្នះជ័យក្រោម៥០០ម |
| 8 | 536115 | 1230945 | ដើមរាំង |
| 9 | 536666 | 1233546 | កែងព្រែកចុង |

| | | | |
|---|---|---|---|
| 10 | 534754 | 1234255 | ស្ពានព្រែកចុង |
| 11 | 534760 | 1234543 | ខាងជើងព្រែកចុង |

កន្លែងត្រីមេពូជទួលអ្នកតាស្វាយ

| id | x | y |
|---|---|---|
| 1 | 534364 | 1228386 |
| 2 | 534362 | 1228375 |
| 3 | 534466 | 1228375 |
| 4 | 534466 | 1228390 |

កន្លែងអភិរក្សព្រៃលិចទឹកទួលអ្នកតាស្វាយ

| id | x | y |
|---|---|---|
| 1 | 534367 | 1228396 |
| 2 | 534363 | 1228369 |
| 3 | 534466 | 1228389 |
| 4 | 534468 | 1228370 |

ដូចផែនទីដែលបានភ្ជាប់មកជាមួយ ។

**ប្រការ ៣.-**

ភាគី **ក** ត្រូវបំពេញភារកិច្ចជា អ្នកជួយសម្របសម្រួល ផ្ដល់បច្ចេកទេស ទប់ស្កាត់បទល្មើស តាមដាននិងត្រួតពិនិត្យលើការរៀបចំ និង ការប្រព្រឹត្តទៅរបស់សហគមន៍នេសាទ ដូចមានចែងនៅក្នុងមាត្រា២៣ នៃអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ ។

**ប្រការ ៤.-**

ភាគី **ខ** ត្រូវរៀបចំ៖

- កន្លែងអភិរក្សព្រៃលិចទឹក
- ស្រះ អាង អន្លង់ត្រីមេពូជ
- កន្លែងអភិរក្សជីវចំរុះ
- ស្តារប្រឡាយ ព្រែក បឹង ស្រះ
- ដាំព្រៃលិចទឹក
- ធ្វើវារីវប្បកម្ម
- បញ្ជូនសមាជិកសហគមន៍ដើម្បីរៀនសូត្រនូវបច្ចេកទេសផលិតពូជត្រី
- ការងារអភិវឌ្ឍន៍ផ្សេងៗទៀត ។

**ប្រការ ៥.-**

ភាគី **ខ** ត្រូវរៀបចំប្រជុំពិភាក្សាអំពីទំហំ ចំនួន ប្រវែង និង ប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ឱ្យសមស្របតាមស្ថានភាពភូមិសាស្ត្រ និង ពេលវេលា ផ្អែកតាមច្បាប់ស្ដីពីជលផលនឹងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធ ។

**ប្រការ ៦.-**

ភាគី **ខ** មានកាតព្វកិច្ចថែរក្សាការពារធនធានធម្មជាតិដូចខាងក្រោម៖

- ការពារព្រៃលិចទឹកដែលមានស្រាប់ឱ្យបានគង់វង្ស ចាត់វិធានការទប់ស្កាត់ និង បង្ការភ្លើង ឆេះព្រៃ

- រក្សានិងការពារដីទំនាបលិចទឹកសម្រាប់ដាំព្រៃលិចទឹកឡើងវិញ
- លែងទៅក្នុងធម្មជាតិវិញ នូវវារីសត្វដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជនៅពេលដែលធ្វើនេសាទបាន
- ការពារសត្វព្រៃគ្រប់ប្រភេទនៅក្នុងដែននេសាទឬព្រៃលិចទឹក ។

**ប្រការ ៧.-**

ភាគី **ខ** មិនត្រូវធ្វើសកម្មភាពដែលបង្កឱ្យខូចដែននេសាទឬគ្រោះថ្នាក់ដល់ធនធានជលផលដូចខាងក្រោម៖

- ចាប់នូវធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចជាផ្សោត ជាដើម
- លើកទំនប់ លុប ឬ ជីក បឹង ព្រែក ប្រឡាយ រណ្ដៅ បៀ ស្រះ ដែលពុំមានការអនុញ្ញាតពីស្ថាប័នជំនាញ
- កាប់ ឆ្ការ គាស់ រាន ឈូសឆាយព្រៃលិចទឹកក្នុងគោលបំណងហ៊ុំព័ទ្ធយកដីជាកម្មសិទ្ធិ ឬ រាតដីធ្វើស្រែ ចំការ ឬគោលបំណងផ្សេងៗឡើយ
- ធ្វើនេសាទ កាប់ព្រៃ ឬអុស ក្នុងកន្លែងអភិរក្សជលផល ក្នុងកន្លែងនេសាទសហគមន៍
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ជាពិសេសឧបករណ៍នេសាទឆក់ត្រីនិងឧបករណ៍នេសាទស្បៃមុង គ្រប់ប្រភេទ
- ប្រើប្រាស់ឧបករណ៍នេសាទខុស ពីការកំណត់នៅ ក្នុងតារាងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ
- ចិញ្ចឹមត្រី ដែលជាពូជនាំឱ្យខូចដល់បរិស្ថានធម្មជាតិ បំផ្លិចបំផ្លាញដល់ធនធានជលផលឬបង្កអន្តរាយដល់ដែននេសាទ
- ធ្វើនេសាទ ឬធ្វើអាជីវកម្មផ្សេងៗទៀតដែលប៉ះពាល់ដល់ធនធានជលផល
- ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍ឆក់ ឧបករណ៍នេសាទស្បៃមុង គ្រប់ប្រភេទនិងអួនអួស ទឹកសាប
- ដាំឬថែរក្សាដំណាំឈូកក្នុងដែននេសាទ ធ្វើនេសាទដោយមងឬអួនគ្រប់ប្រភេទដែលមានក្រឡាតូចជាង ១.៥ សង្ទីម៉ែត្រនិងធំជាងដប់ប្រាំ(១៥)សង្ទីម៉ែត្រ ក្នុងដែននេសាទទឹកសាប ។

**ប្រការ ៨.-**

ភាគី **ខ** ត្រូវចាត់វិធានការថែរក្សាការពារកន្លែងនេសាទសហគមន៍ដោយបំផុស ជំរុញនិងលើកទឹកចិត្តដល់សមាជិកសហគមន៍នេសាទគ្រប់រូបឱ្យរាយការណ៍ទៅសមត្ថកិច្ចរដ្ឋបាលជលផល ដែលនៅជិតបំផុតដើម្បីសហការទប់ស្កាត់បទល្មើសជលផល ។

**ប្រការ ៩.-**

ភាគី **ខ** ត្រូវអនុវត្តនូវភារកិច្ចដូចខាងក្រោម៖

- ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់តាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងនិងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ធានាឱ្យសមាជិកទាំងអស់ក្នុងសហគមន៍ មានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផល
- សហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់និងអាជ្ញាធរដែលពាក់ព័ន្ធ ។

**ប្រការ ១០.-**

ប្រសិនបើភាគី **ខ** មិនអនុវត្តតាមប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ធ្វើឱ្យអន្តរាយដល់ដែននេសាទឬធនធានជលផលត្រូវទទួលខុសត្រូវ ចំពោះមុខច្បាប់ជាធរមាន ។

**ប្រការ ១១.-**

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ អាចបញ្ឈប់មុនពេលកំណត់ដោយផ្អែកលើលក្ខខណ្ឌណាមួយដូចមានចែងក្នុងមាត្រា២៧ នៃអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍-នេសាទ ។

ក្នុងករណីដែលសហគមន៍នេសាទយល់ថាការបញ្ឈប់កិច្ចព្រមព្រៀងពុំមានលក្ខណៈសមស្របសហគមន៍នេសាទអាចធ្វើការតវ៉ាមកប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ។

**ប្រការ ១២.-**

កិច្ចព្រមព្រៀងនេះ អាចធ្វើការកែប្រែបានតាមការឯកភាពរបស់ ភាគីទាំង២ ស្របតាមច្បាប់និងលិខិតបទដ្ឋាន-នានាពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

កិច្ចព្រមព្រៀងនេះត្រូវតម្កល់ទុកនៅស្នាក់ការសហគមន៍នេសាទ សាលាឃុំ ខណ្ឌរដ្ឋបាលជលផល សាលាខេត្តក្រុង រដ្ឋបាលជលផលថ្នាក់កណ្តាល និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទហើយអាចចម្លងជូនស្ថាប័នពាក់ព័ន្ធដោយច្បាប់ចម្លងត្រូវមានប្រថាប់ត្រា ។

ភូមិតាម៉ៅ ថ្ងៃទី..11... ...ខែ06... ឆ្នាំ២០១៣

ភាគី ក

**នាយខណ្ឌរដ្ឋបាលជលផលព្រៃវែង**

ហត្ថលេខា

អ៊ុន_ស៊ីណាត

ភាគី ខ

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ហត្ថលេខា

ប៉ម សុខុម

សាក្សី

**មេឃុំរាធរ**

ហត្ថលេខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនទីកន្លែងនេសាទសហគមន៍

ឈ្មោះសហគមន៍នេសាទ : រាធរ
ភូមិ : ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ
ឃុំ : រាធរ
ស្រុក : ព្រះស្ដេច
ខេត្ត : ព្រៃវែង

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ  សាសនា  ព្រះមហាក្សត្រ

# ផែនទីកន្លែងនេសាទសហគមន៍

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : រាធរ |
| ភូមិ | : ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ |
| ឃុំ | : រាធរ |
| ស្រុក | : ព្រះស្ដេច |
| ខេត្ត | : ព្រៃវែង |

# ផែនទីកន្លែងនេសាទសហគមន៍រាធរ

## ភូមិឈ្នះជ័យលើ ភូមិឈ្នះជ័យក្រោម ភូមិតាម៉ៅ ឃុំរាធរ ស្រុកព្រះស្ដេច ខេត្តព្រៃវែង




**សញ្ញាសំគាល់**

| | |
|---|---|
| ក) ព្រៃក្រាស់ឬព្រៃធំ ខ) ព្រៃស្ដើង | ស្រុក |
| ក) ព្រៃគុម្ពោត ខ) វាលស្មៅ | ឃុំ |
| វាលស្មៅលិចទឹក | ភូមិ |
| ព្រៃគុម្ពោតលិចទឹក | ផ្លូវក្រាលថ្ម |
| ព្រៃលិចទឹក | ផ្លូវលំ ផ្លូវក្រាយទទឹងតូចជាង២.៤ម |
| ទំនាបបឹង | ផ្លូវជើង |
| ក) វាលស្រែ ខ) វាលស្រែលិចទឹក | កន្លែងនេសាទសហគមន៍ |
| ក) ចំការ ខ) ដំណាំក្នុងភូមិ | រាធរ ទំហំ ៦៦៩ ហត |
| ទន្លេ ស្ទឹង បឹងឬត្រពាំង | កន្លែងអភិរក្សជលផល |
| ក) ទឹកខួប ខ) ទឹកមិនខួប | កន្លែងអភិរក្សព្រៃលិចទឹក |

**តារាងនិយាមកា**

| ID | X_coor | Y_coor |
|---|---|---|
| 1 | 537545 | 1233438 |
| 2 | 537529 | 1231002 |
| 3 | 534769 | 1228303 |
| 4 | 534198 | 1228210 |
| 5 | 533905 | 1229367 |
| 6 | 534214 | 1229675 |
| 7 | 535093 | 1229645 |
| 8 | 536115 | 1230945 |
| 9 | 536666 | 1233546 |
| 10 | 534754 | 1234255 |
| 11 | 534760 | 1234543 |

| ID | X_coor | Y_coor |
|---|---|---|
| | ចំណុចកំណត់កន្លែងអភិរក្សជលផល | |
| 1 | 534364 | 1228386 |
| 2 | 534362 | 1228375 |
| 3 | 534466 | 1228375 |
| 4 | 534466 | 1228390 |
| | ចំណុចការកន្លែងអភិរក្សព្រៃលិចទឹក | |
| 1 | 534367 | 1228396 |
| 2 | 534363 | 1228369 |
| 3 | 534466 | 1228389 |
| 4 | 534468 | 1228370 |

មាត្រដ្ឋាន ១/ ៥០០០០

COORDENATION SYSTEM

-Projection :................ UTM
-Zone :...........................48 N
-Datum :............... Indian 60
-Spheroid :............... Everest
-Unit :........................ Meter

០ ០.៥ ១ ២គម

......ថ្ងៃទី...9...ខែ...5...ឆ្នាំ2013
មេភូមិតាម៉ៅ

......ថ្ងៃទី09....ខែ05..ឆ្នាំ2013
មេភូមិឈ្នះជ័យក្រោម

បានឃើញនិងគោរពជូន
លោកមេឃុំរាធរ
"ដើម្បីជូនពិនិត្យនិងសម្រួល"
......ថ្ងៃទី09....ខែ05..ឆ្នាំ2013
មេភូមិឈ្នះជ័យលើ

សូមគោរពជូន
លោកមេភូមិពាក់ព័ន្ធ
"ដើម្បីជូនពិនិត្យនិងសម្រួល"
......ថ្ងៃទី09....ខែ05..ឆ្នាំ2013
ប្រធានគណៈកម្មការសហគមន៍នេសាទរាធរ

លេខ : 19/2013
បានឃើញនិងគោរពជូន
លោកអភិបាលនៃគណៈអភិបាលស្រុកព្រះស្ដេច
"ដើម្បីជូនពិនិត្យនិងសម្រួល"
......ថ្ងៃទី06...ខែ06..ឆ្នាំ2013
នាយផ្នែករដ្ឋបាលជលផលស្ទឹងស្លូត

បានឃើញនិងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលស្ទឹងស្លូត
"ដើម្បីជូនពិនិត្យនិងសម្រួល"
......ថ្ងៃទី10...ខែ05..ឆ្នាំ2013
នាយសង្កាត់រដ្ឋបាលជលផលព្រះស្ដេច

លេខ : ..08/13....
បានឃើញនិងគោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលព្រះស្ដេច
"ដើម្បីជូនពិនិត្យនិងសម្រួល"
......ថ្ងៃទី..10...ខែ...5...ឆ្នាំ..2013
មេឃុំរាធរ

លេខ : ..១២០........ រ.ប.ខ
បានឃើញនិងគោរពជូន
ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង
"ដើម្បីជូនពិនិត្យនិងសម្រួល"
......ថ្ងៃទី..០៥..ខែ..០៧..ឆ្នាំ..២០១៤
នាយអធិការដ្ឋានរដ្ឋបាលជលផលចតុមុខ

លេខ ......................
បានឃើញនិងគោរពជូន
លោកនាយអធិការដ្ឋានរដ្ឋបាលជលផលចតុមុខ
"ដើម្បីជូនពិនិត្យនិងសម្រួល"
......ថ្ងៃទី..........ខែ..........ឆ្នាំ..២០១៤
នាយខណ្ឌរដ្ឋបាលជលផលព្រៃវែង

លេខ : 021/014
បានឃើញនិងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលព្រៃវែង
"ដើម្បីជូនពិនិត្យនិងសម្រួល"
......ថ្ងៃទី..០៤...ខែ..០៤...ឆ្នាំ..២០១៤
អភិបាលនៃគណៈអភិបាលស្រុកព្រះស្ដេច

លេខ : ......................
បានឃើញនិងគោរពជូន
ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
"ដើម្បីជូនពិនិត្យនិងសម្រេច"
......ថ្ងៃទី..........ខែ..........ឆ្នាំ..........
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល

លេខ : ......................
បានឃើញនិងគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីជូនពិនិត្យនិងសម្រួល"
......ថ្ងៃទី..........ខែ..........ឆ្នាំ..........
អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

លេខ : ..០០៣.......កសក
បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី..០៦....ខែ..មករា..ឆ្នាំ....២០១៦
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីឈ្មោះសមាជិកនិងគណៈកម្មការ
# សហគមន៍នេសាទ និងរចនាសម្ព័ន្ធ

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : រាធរ |
| ភូមិ | : ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ |
| ឃុំ | : រាធរ |
| ស្រុក | : ព្រះស្ដេច |
| ខេត្ត | : ព្រៃវែង |

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីឈ្មោះសមាជិកនិងគណៈកម្មការ សហគមន៍នេសាទ និងរចនាសម្ព័ន្ធ

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : រាធរ |
| ភូមិ | : ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ |
| ឃុំ | : រាធរ |
| ស្រុក | : ព្រះស្តេច |
| ខេត្ត | : ព្រៃវែង |

# បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទរាធរ

## ភូមិឈ្នះជ័យលើ ឈ្នះជ័យក្រោម ភូមិតាម៉ៅ ឃុំរាធរ ស្រុកព្រះស្តេច ខេត្តព្រៃវែង

| ល.រ | នាមនិងគោត្តនាម | ភេទ | អាយុ | ភូមិ | ឃុំ | ស្រុក | មុខរបរ | ថ្ងៃ ខែ ឆ្នាំ ធ្វើមហាសន្និបាតអំណើតដំបូង |
|---|---|---|---|---|---|---|---|---|
| ១ | មាស ឆេង | ប | ៦១ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ២ | ព្រុំ ប៊ីម | ស | ៣៥ | ឈ្នះជ័យលើ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៣ | គង់ សិទ្ធិ | ប | ៣៨ | ឈ្នះជ័យលើ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៤ | ស សារ៉េន | ប | ៤០ | ឈ្នះជ័យលើ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៥ | សុខ សារ៉ុម | ប | ៤៥ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៦ | យុត ជឹម | ប | ៦១ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៧ | ភុន សារុន | ប | ៥២ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៨ | អ៊ំ ជុំ | ប | ៥០ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៩ | សួង សាប | ប | ៣៥ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ១០ | ឃ្លោក សំណាង | ប | ៣៣ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ១១ | ឈាន ឈោ | ប | ៣២ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ១២ | ស៊ិន សួ | ប | ៣៨ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ១៣ | ហ៊ីង ហេង | ប | ៦០ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ១៤ | អេង អាង | ប | ៥៩ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ១៥ | ម៉ាក ម៉ន | ប | ៦៨ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ១៦ | វ៉ិន វេ | ប | ៤៦ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ១៧ | កាន់ គង់ | ប | ៣៩ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ១៨ | ឃ្លោ រ៉េង | ស | ៤១ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ១៩ | ប៊ុត ផុន | ប | ៥៩ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ២០ | អ៊ាប ស៊ឹង | ប | ៣២ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ២១ | យឹម ផេស | ប | ៦៨ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ២២ | ម៉ម សុខុម | ប | ៥៣ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ២៣ | ហោ ម៉ី | ប | ៦២ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ២៤ | ជា មើក | ប | ៦៨ | ឈ្នះជ័យលើ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ២៥ | ឃ្លោក សារ៉េង | ស | ៥៣ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ២៦ | ប្បៀ កាន | ស | ៥៥ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ២៧ | អ៊ំ នុ | ស | ៣៣ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ២៨ | ចន ហួយ | ស | ៥១ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ២៩ | ស៊ុន យង់ | ស | ៦២ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៣០ | ស៊ាប ចន្ទី | ស | ២៨ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៣១ | សន ហ៊ុន | ស | ៥៥ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣២ | ស៊ាប សឹង | ប | ៣១ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៣៣ | ស៊ាប ចំណាន | ប | ៣៧ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៣៤ | ថៃ វមន | ប | ២០ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៣៥ | មល សាឡុង | ប | ៣២ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៣៦ | សុង ហ៊ាង | ស | ៤៥ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៣៧ | ផុន ភឿន | ស | ៣៧ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៣៨ | អាត ណាន | ស | ៤៣ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៣៩ | ខន ភ័ណ | ស | ៣២ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៤០ | ភួន សាមាន | ស | ៤៨ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៤១ | ស៊ុន យិន | ស | ៥៣ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៤២ | រី ស | ស | ៣៥ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៤៣ | រឿន ស្រីពៅ | ស | ២៧ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៤៤ | រី ណាត | ស | ៤៦ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៤៥ | សួន លន់ | ស | ៦៣ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៤៦ | បូ សាល | ស | ៥៣ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៤៧ | ខេង វ៉េត | ស | ៣៥ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៤៨ | មល សាម៉េត | ស | ២៨ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៤៩ | សៀង ផាម | ស | ៥៥ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៥០ | ម៉ា អិម | ស | ៥៥ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៥១ | ស្មោញ ម៉ាន | ប | ៣៩ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៥២ | សំ អុល | ស | ២៦ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៥៣ | ដេន ឌុល | ប | ២៤ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៥៤ | សន់ នាថ | ស | ២៦ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៥៥ | ហួន សាម៉េត | ស | ៣២ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៥៦ | សុំ អឿន | ស | ៤៥ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៥៧ | សុំ ស៊ុន | ស | ៥០ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៥៨ | អៀម ម៉ាលី | ស | ៤៦ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៥៩ | ហួត សាមន | ស | ៥០ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៦០ | សុន ហួន | ស | ៥៥ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៦១ | រឿន ច្រឹប | ស | ២៩ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៦២ | ម៉ៃ សាវុន | ស | ២៩ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៦៣ | យ៉ុំ យេត | ស | ៣៤ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៦៤ | សុន សាវ៉ាន | ស | ៥៤ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៦៥ | ឌុម សារ៉ុម | ស | ២៨ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៦៦ | វៃ សាវី | ស | ៣១ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៦៧ | ម៉ម សុភាព | ស | ៣៧ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៦៨ | ព្រុំ ស្រីពៅ | ស | ៤០ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៦៩ | ប៊ុន លីម | ប | ៤៧ | ឈ្នះជ័យលើ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៧០ | អ៊ុច អាន | ប | ៦០ | ឈ្នះជ័យលើ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៧១ | ចាន្ថា ដានី | ស | ២០ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |
| ៧២ | ឆយ គង់ | ប | ៧៨ | តាម៉ៅ | រាធរ | ព្រះស្តេច | ធ្វើស្រែនិងនេសាទ | ២៧/០៤/២០១២ |

សមាជិកសរុបៈ ៧២នាក់

ប្រុសៈ ៣១នាក់

ស្រីៈ៤១នាក់

បានឃើញ និងចុះបញ្ជី

ថ្ងៃទី..០៩........ខែមេសា ឆ្នាំ២០១៣

**ប្រធានគណៈកម្មការសហគមន៍នេសាទរាធរ**

ហត្ថលេខា

ង៉ែង សុខុម

បានឃើញ និង ឯកភាព

ឈ្មោះនៅក្នុងបញ្ជីខាងលើនេះ ពិតប្រាកដជា

សមាជិកសហគមន៍នេសាទ**រាធរ** ពិតប្រាកដមែន

**មេឃុំរាធរ**

ឈូក ម៉ុច

# បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទរាធរ

ភូមិឈ្នះជ័យលើ ឈ្នះជ័យក្រោម ភូមិតាម៉ៅ ឃុំរាធរ ស្រុកព្រះស្ដេច ខេត្តព្រៃវែង

| ល.រ | នាមគោត្តនាម | ភេទ | អាយុ | ភូមិ | ឃុំ | តួនាទី | ហត្ថលេខា |
|---|---|---|---|---|---|---|---|
| ១ | ម៉ម សុខុម | ប្រុស | ៥៥ | តាម៉ៅ | រាធរ | ប្រធានគណៈកម្មការសហគមន៍នេសាទ | |
| ២ | អ៊ុំ ជុំ | ប្រុស | ៤៩ | តាម៉ៅ | រាធរ | អនុប្រធានគណៈកម្មការសហគមន៍នេសាទ | |
| ៣ | ព្រុំ យឹម | ស្រី | ៣៧ | ឈ្នះជ័យលើ | រាធរ | ទទួលបន្ទុកទំនាក់ទំនងគម្រោង | |
| ៤ | ឃ្លោក សំណាង | ប្រុស | ៣៤ | តាម៉ៅ | រាធរ | ទទួលបន្ទុកគណនេយ្យ | |
| ៥ | សួង ស៊ាប | ប | ៣៥ | តាម៉ៅ | រាធរ | ទទួលបន្ទុកផ្សព្វផ្សាយ | |
| ៦ | វិន វៃ | ប្រុស | ៤៥ | តាម៉ៅ | រាធរ | ទទួលបន្ទុកកែច្នៃផលនេសាទ | |
| ៧ | ភុន សារុន | ប្រុស | ៥១ | តាម៉ៅ | រាធរ | ទទួលបន្ទុកវាយតលៃផលចាប់ | |
| ៨ | ឈាន ឈា | ប្រុស | ៣៥ | តាម៉ៅ | រាធរ | ទទួលកិច្ចការរដ្ឋបាល | |
| ៩ | ហ៊ីង ហេង | ប្រុស | ៥៥ | តាម៉ៅ | រាធរ | ទទួលបន្ទុករអភិរក្សធនធានជលផល | |
| ១០ | ភាន់ ខឿន | ប្រុស | ៤២ | ឈ្នះជ័យក្រោម | រាធរ | ទទួលបន្ទុកតាមដាននិងវាយតម្លៃសហគមន៍នេសាទ | |
| ១១ | រស់ រុម | ប្រុស | ៤៥ | ឈ្នះជ័យក្រោម | រាធរ | ទទួលបន្ទុកវិវាទ | |

ភូមិតាម៉ៅ ថ្ងៃទី០១.៤.........ខែមេសា ឆ្នាំ២០១៣

**ប្រធានគណៈកម្មការសហគមន៍នេសាទរាធរ**

ម៉ម សុខុម

បានឃើញ និង បញ្ជាក់ថា
ឈ្មោះនៅក្នុងបញ្ជីខាងលើនេះ ពិតប្រាកដ
ជាគណៈកម្មការ និងសមាជិកគណៈកម្មការ
សហគមន៍នេសាទរាធរ ពិតប្រាកដមែន

**មេឃុំរាធរ**




**សមាសភាពគណៈកម្មការសហគមន៍នេសាទរាជរ**

ក-លោកៈម៉ែសុខុម៉ប្រធានគណៈកម្មការសហគមន៍នេសាទរាជរ

- ស្វែងរកជំនួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស ហិរញ្ញវត្ថុពីសមត្ថកិច្ចជលផល ស្ថាប័នជំនាញ និងអង្គការជាតិ
- គ្រប់គ្រងនិងដឹកនាំការងាររួមក្នុងសហគមន៍នេសាទទាំងមូល
- ដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានក្នុងសហគមន៍នេសាទ
- រៀបចំការប្រជុំគណៈកម្មការសហគមន៍និងសន្និបាតសហគមន៍នេសាទឱ្យបានទៀងទាត់
- រៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មការអណត្តិក្រោយតាមការកំណត់
- ទទួលខុសត្រូវរាល់ការចំណាយ ទៅតាមផែនការរបស់មហាសន្និបាតកំណត់
- ផ្ទេរភារកិច្ចជាលាយលក្ខណ៍អក្សរទៅអនុប្រធាន ។

ខ-លោកៈអុំ ជុំ អនុប្រធានគណៈកម្មការសហគមន៍នេសាទ

- ជួសមុខប្រធាននៅពេលប្រធានអវត្តមាន
- ទទួលភារកិច្ចផ្សេងៗ ដែលប្រធានប្រគល់ជូន ។

គ-លោកស្រីៈ ព្រំ **ឃីម** សមាជិកគណៈកម្មការទទួលបន្ទុកទំនាក់ទំនងគម្រោង

- ពិនិត្យលើផែនការគ្រប់គ្រង កិច្ចព្រមព្រៀង លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- ទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាល និងក្នុងរដ្ឋាភិបាល
- សរសេរសំណើរទៅអង្គការក្រៅរដ្ឋាភិបាល និងក្នុងរដ្ឋាភិបាល
- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន

ឃ-លោកៈ**ឃ្លោក សំណាង** សមាជិកគណៈកម្មការទទួលបន្ទុកគណនេយ្យ

- ទទួលខុសត្រូវហិរញ្ញវត្ថុក្នុងសហគមន៍នេសាទ
- ធ្វើបញ្ជីចំណូល ចំណាយ របស់សហគមន៍នេសាទឱ្យបានត្រឹមត្រូវ
- រៀបចំរបាយការណ៍ពីស្ថានភាពចំណូល ចំណាយជូនប្រធានគណៈកម្មការជារៀងរាល់ខែ
- រក្សាទុករាល់ឯកសារចំណូល ចំណាយរបស់សហគមន៍នេសាទ
- រៀបចំគម្រោងផែនការ ប្រើប្រាស់ហិរញ្ញវត្ថុសហគមន៍នេសាទ
- រាល់ការចំណាយត្រូវមានការឯកភាពពីប្រធានឬគណៈកម្មការសហគមន៍នេសាទ
- រាល់ការចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីប័ននិងចុះបញ្ជីឲ្យបានត្រឹមត្រូវ
- ថវិកាដែលត្រូវចំណាយ គឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍នេសាទ ។

ង-លោកៈសួង ស៊ាប សមាជិកគណៈកម្មការសហគមន៍ទទួលបន្ទុកផ្សព្វផ្សាយ

- ផ្សព្វផ្សាយលក្ខន្តិកៈ បទបញ្ញាផ្ទៃក្នុង ផែនការគ្រប់គ្រងនិងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ផ្សព្វផ្សាយពីកន្លែងអភិរក្សត្រីមេពូជ
- ផ្សព្វផ្សាយច្បាប់ស្តីពីជលផលនិងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធសហគមន៍នេសាទ
- ផ្សព្វផ្សាយអំពីផែនការប្រើប្រាស់ឧបករណ៍នេសាទ
- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ឱ្យយល់ពីផលប្រយោជន៍សហគមន៍នេសាទ
- ផ្សព្វផ្សាយនិងជូនដំណឹងដល់សមាជិកស្តីពី ការប្រមូលភាគទានប្រចាំ
- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន

ច-លោកៈរិន វ៉ៃ សមាជិកគណៈកម្មការសហគមន៍ទទួលបន្ទុកកែច្នៃផលនេសាទ និងវារីវប្បកម្ម

- ពន្យល់ដល់សមាជិកសហគមន៍នេសាទពីរបៀបរក្សាត្រីបានយូរ
- ពីរបៀបធ្វើ ប្រហុក ផ្អក ត្រីឆ្អើរ និងត្រីងៀត ។
- របៀបជីកស្រះ របៀបរក្សាកូនត្រី ប្រភេទកូនត្រី ប្រភេទទឹក របៀបលែងកូនត្រី និងទំហំស្រះ ។
- ការចិញ្ចឹមត្រីតាមស្រែ
- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន

ឆ-លោកភុន សារុន សមាជិកគណៈកម្មការទទួលបន្ទុកវាយតម្លៃផលចាប់ត្រីប្រចាំឆ្នាំ

- តាមដានប្រភេទត្រី
- ធ្វើស្ថិតិឧបករណ៍នេសាទរបស់សមាជិកសហគមន៍ និងអ្នកនេសាទខាងក្រៅ
- ធ្វើការបូកសរុបផលចាប់ត្រីប្រចាំឆ្នាំ
- ទទួលភារកិច្ចផ្សេងៗ ដែលប្រធានប្រគល់ជូន

ជ-លោកៈឈាន ឈា សមាជិកគណៈកម្មការទទួលបន្ទុកកិច្ចការរដ្ឋបាល

- ធ្វើកំណត់ហេតុនិងរបាយការណ៍
- ពិនិត្យពាក្យស្នើសុំចូលជាសមាជិកសហគមន៍នេសាទ
- ធ្វើលិខិតអញ្ជើញសមាជិកសហគមន៍នេសាទឲ្យចូលរួមមហាសន្និបាតសាមញ្ញ
- ធ្វើរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រង និងរក្សាទុកឯកសារផ្សេងៗ
- រៀបចំបញ្ជីរាយនាមគណៈកម្មការនិងសមាជិកសហគមន៍នេសាទ
- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន

ឈ-លោកៈ ហ៊ីង ហេង សមាជិកគណៈកម្មការទទួលបន្ទុកក្រុមល្បាតនិងអភិរក្សធនធានជលផល

- លោកៈ ឆ៊ាន-រ៉ប់-ប-អាយុ43 សមាជិកក្រុមល្បាត
- លោកៈ ឆ៊ាប ស៊ុំ-ប- 32 សមាជិកក្រុមល្បាត
- លោកៈ ស៊ុន ស៊ូ . ប. 38 សមាជិកក្រុមល្បាត
- លោកៈ អ៊ំ សៅ. ប. 31 សមាជិកក្រុមល្បាត
- លោកៈ ភឿន សឿន ប. 32 សមាជិកក្រុមល្បាត
- លោកៈ ម៉ី រ៉ានី - ប- 21 សមាជិកក្រុមល្បាត
- លោកៈ វ៉ុន វិន. ប. 20 សមាជិកក្រុមល្បាត

- លោកៈ សយ វិន-ប-អាយុ-45 សមាជិកក្រុមល្បាត

- លោកៈ ឌី សារិន-ប-47 សមាជិកក្រុមល្បាត

-លោកៈ ........................................សមាជិកក្រុមល្បាត

- លោកៈ ........................................សមាជិកក្រុមល្បាត

-ចុះយាមល្បាតដើម្បីទប់ស្កាត់នូវរាល់សកម្មភាពបទល្មើសជលផលដែលកើតមាននៅកន្លែងនេសាទសហគមន៍ និងកន្លែងអភិរក្សត្រីមេពូជ ។

- រាយការណ៍និងផ្តល់ព័ត៌មានជាបន្ទាន់នូវរាល់បទល្មើសជលផលនៅកន្លែងនេសាទសហគមន៍ ដល់សមត្ថកិច្ចជលផលដែលនៅជិតបំផុត ។

-សហការណ៍ជាមួយសមត្ថកិច្ចជលផលដើម្បីបង្ក្រាបរាល់បទល្មើសជលផលនៅក្នុងកន្លែងសហគមន៍នេសាទ

-ករណីចាំបាច់ក្រុមល្បាតអាចស្នើសុំអន្តរាគមន៍ពីសមត្ថកិច្ចនៅជិតដើម្បីឃាត់ទុកវត្ថុតាងនៃបទល្មើសនិងឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសរួចបញ្ជូនទៅសមត្ថកិច្ចជលផលដើម្បីដោះស្រាយបទល្មើសតាមច្បាប់ ។

-មិនត្រូវប្រមូលប្រាក់ពិន័យឬរឹបអូសវត្ថុតាងនៃបទល្មើសជលផលដោយផ្ទាល់ឡើយ ។

-ធ្វើកំណត់ហេតុបទល្មើសនេសាទ ។

-ធ្វើរបាយការណ៍ពីសកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍ ជូនទៅប្រធានគណៈកម្មការរៀងរាល់ខែ ។

- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន

ញ-លោកៈ **វ៉ាន់ ខឿន** សមាជិកគណៈកម្មការទទួលបន្ទុកតាមដាននិងវាយតម្លៃការអភិវឌ្ឍន៍សហគមន៍នេសាទ

- ពិនិត្យលើផែនការគ្រប់គ្រង និងតាមដានផែនការដែលបានអនុវត្ត
- រាយការណ៍ជូនប្រធាននៅពេលផែនការសកម្មភាពណាមួយមិនរលូន
- ពិនិត្យផែនការសម្រាប់ឆ្នាំនីមួយៗ
- ពន្យល់ផែនការសកម្មភាពដល់អង្គប្រជុំ
- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន

ដ-លោកៈ **រស់ រុម** សមាជិកគណៈកម្មការទទួលបន្ទុកវិវាទ

- ដោះស្រាយទំនាស់រវាងសហគមន៍ និងសហគមន៍អំពីព្រំប្រទល់កន្លែងនេសាទសហគមន៍
- ដោះស្រាយទំនាស់រវាងអ្នកនេសាទខាងក្នុង និងអ្នកនេសាទខាងក្រៅ
- ទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដី (ឃុំដែលនៅជាប់កន្លែងនេសាទសហគមន៍ )
- ទំនាក់ទំនងល្អជាមួយប្រទេសជិតខាង
- ដោះស្រាយទំនាស់ការប្រើប្រាស់ឧបករណ៍នេសាទ
- ដោះស្រាយទំនាស់ការធ្វើនេសាទឆ្លងដែន
- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន

**ប្រការ១-**

បុគ្គលដែលត្រូវជាឪពុកម្តាយបងប្អូនបង្កើតបងប្អូនជីដូនមួយ ប្តី ប្រពន្ធ ជាមួយនឹងប្រធានគណៈកម្មការសហគមន៍នេសាទពុំអាចចាត់តាំងឱ្យធ្វើជាសមាជិកគណៈកម្មការ ទទួលបន្ទុកគណនេយ្យ ឬ បេឡាបានទេ

**ប្រការ២-**

គណៈកម្មការសហគមន៍នេសាទ ស្ម័គ្រចិត្តបំពេញការងារសហគមន៍នេសាទ ដោយពុំទទួលប្រាក់ខែ ពី

សហគមន៍នេសាទ

**ប្រការ៣-**

គណៈកម្មការសហគមន៍នេសាទ ត្រូវធ្វើការប្រជុំយ៉ាងតិចក្នុងមួយខែមួយម្តង ក្នុងករណីចាំបាច់គណៈកម្មការសហគមន៍នេសាទធ្វើការប្រជុំពិសេស ។

**ប្រការ៤-**

ប្រធានគណៈកម្មការសហគមន៍នេសាទជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំសហគមន៍នេសាទ

ក្នុងករណី ប្រធានគណៈកម្មការសហគមន៍នេសាទ អវត្តមាន សមាជិកគណៈកម្មការសហគមន៍នេសាទ ដែលមានឋានានុក្រមបន្ទាប់ ត្រូវធ្វើជាប្រធានអង្គប្រជុំជំនួស ។

ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យ និងមានរបៀបរៀបរយ ។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះចចេសរឹងរូសធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ ។

សេចក្តីសម្រេចនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

លេខៈ ០៩/13........

បានឃើញ និងឯកភាព

មេឃុំរាធរ

បានឯកភាពបែងចែកតួនាទីនិងភារកិច្ចដោយស្ម័គ្រចិត្ត

ភូមិតាម៉ៅ ថ្ងៃទី២៧........ខែ០៥..... ឆ្នាំ២០១៣

ប្រធានគណៈកម្មការសហគមន៍នេសាទរាធរ

ម៉ឹម សុខុម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈសហគមន៍នេសាទ

ឈ្មោះសហគមន៍នេសាទ : រាធរ
ភូមិ : ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ
ឃុំ : រាធរ
ស្រុក : ព្រះស្ដេច
ខេត្ត : ព្រៃវែង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈសហគមន៍នេសាទ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | : | រាធរ |
| ភូមិ | : | ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ |
| ឃុំ | : | រាធរ |
| ស្រុក | : | ព្រះស្ដេច |
| ខេត្ត | : | ព្រៃវែង |

# ជំពូកទី ១
# គោលបំណង និងនាមករណ៍

**ប្រការ ១.-**

លក្ខន្តិកៈនេះមានគោលបំណង៖

- កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ ការប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព
- ធ្វើជាគោលការណ៍គ្រឹះនិងជាយន្តការសម្រាប់ដំណើរការសហគមន៍នេសាទ
- ការពារសិទ្ធិនិងផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទនិងផលប្រយោជន៍សាធារណៈ ។

**ប្រការ ២.-**

ឈ្មោះសហគមន៍នេសាទ**រាធរ** ហៅកាត់ថា ( **ស គ រ ធ**) អាសយដ្ឋានភូមិឈ្នះជ័យលើ ឃុំរាធរ ស្រុកព្រះស្តេច ខេត្តព្រៃវែង ។

សហគមន៍នេសាទនេះ មានការចូលរួមពីប្រជាពលរដ្ឋដែលរស់នៅក្នុង៖

- ភូមិឈ្នះជ័យលើ ឃុំរាធរ ស្រុកព្រះស្តេច ខេត្តព្រៃវែង
- ភូមិឈ្នះជ័យក្រោម ឃុំរាធរ ស្រុកព្រះស្តេច ខេត្តព្រៃវែង
- ភូមិតាម៉ៅ ឃុំរាធរ ស្រុកព្រះស្តេច ខេត្តព្រៃវែង

**មានកម្មវត្ថុ៖** ដើម្បីថែរក្សា ការពារ ប្រើប្រាស់ អភិរក្ស អភិវឌ្ឍន៍និងគ្រប់គ្រងធនធានជលផល ឱ្យបានយូរអង្វែង ។

# ជំពូកទី ២
# លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភារកិច្ច និងសិទ្ធិរបស់សមាជិក

**ប្រការ ៣.-**

ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងចង់ចូលជាសមាជិកសហគមន៍នេសាទ មានសិទ្ធិដាក់ពាក្យសុំចូលដោយស្ម័គ្រចិត្តនិងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

- មានលំនៅដ្ឋាននៅក្នុងបណ្តាភូមិ នៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំឡើង ។

**ប្រការ ៤.-**

សមាជិកសហគមន៍នេសាទ ដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ៣ ខាងលើមានសិទ្ធិ ៖

- ចូលរួមប្រជុំមហាសន្និបាតនិងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោតនិងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍នេសាទ ស្របតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ
- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចសង្គម របស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ

- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សានិងសម្រេចលើបញ្ហាណាមួយបើមានការស្នើសុំពីសមាជិក យ៉ាងតិចមួយភាគបី(១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់
- ធ្វើនេសាទជាលក្ខណៈគ្រួសារ ស្របតាមច្បាប់ស្តីពីជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ផែនការ-គ្រប់គ្រងកន្លែងនេសាទសហគមន៍និងលិខិតបទដ្ឋានគតិយុត្តិនានា ដែលពាក់ព័ន្ធវិស័យជលផល
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្តឹងតវ៉ាឬផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅសមត្ថ-កិច្ចរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ ។

សមាជិកសហគមន៍នេសាទ ត្រូវទទួលខុសត្រូវរាល់សកម្មភាពរៀងៗខ្លួន និងរួមគ្នាចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ចដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់ (១/១០) ឡើងទៅអាចស្នើសុំឱ្យប្រធានគណៈកម្មការសហគមន៍នេសាទបញ្ចូលបញ្ហាមួយចំនួនទៅក្នុងរបៀបវារៈ នៃកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ សាមី ហើយចំនួនសមាជិកសហគមន៍នេសាទ ដែលបានស្នើសុំខាងលើនេះអាចចាត់តំណាងចំនួនបី(៣)នាក់ ចូលរួមប្រជុំដើម្បីចោទសួរគណៈកម្មការសហគមន៍នេសាទនូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងចំណុចដែលបានស្នើឡើងនោះ ។

**ប្រការ ៥**.-

សមាជិកសហគមន៍នេសាទ មានកាតព្វកិច្ចនិងភារកិច្ចដូចខាងក្រោម ÷

- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល
- អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- អនុវត្តតាមអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ស្តីពីការគ្រប់គ្រងសហគមន៍-នេសាទនិងលិខិតបទដ្ឋានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ
- អនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀងនិងផែនការគ្រប់គ្រងកន្លែងនេសាទ-សហគមន៍
- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាតនិងគណៈកម្មការសហគមន៍នេសាទ
- បង់ប្រាក់សមាជិកភាពចំនួន ៥០០រៀល តាមការសម្រេចរបស់មហាសន្និបាតនៅពេលដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- បង់ប្រាក់ភាគទានប្រចាំឆ្នាំចំនួន ២០០០រៀល តាមការសម្រេចរបស់មហាសន្និបាត
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទ ដើម្បីផលប្រយោជន៍និងការរីកចំរើនរបស់សហគមន៍នេសាទ
- ចូលរួមការពារ ថែរក្សានិងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ
- ចូលរួមឃ្លាំមើលទប់ស្កាត់និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍

## ជំពូកទី ៣
## លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និង ការបណ្តេញចេញពីសមាជិក

**ប្រការ ៦.-**

សមាជិកសហគមន៍នេសាទមានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ ÷

- ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ
- ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ ៧.-**

សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាពក្នុងលក្ខខណ្ឌដូចខាងក្រោម ÷

- ការមិនបង់ភាគទានចំនួន ៣ លើកជាប់ៗគ្នា
- ការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍ នៃសហគមន៍នេសាទ ឬសមាជិកសហគមន៍នេសាទដទៃទៀត
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋឬបទមជ្ឈិម
- សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈឬបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ។

## ជំពូកទី ៤
## របៀបរបបកាន់បញ្ជី និង ឯកសារនានា

**ប្រការ ៨.-**

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី ÷

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការអន្តរជាតិនិងអង្គការមិនមែនរដ្ឋាភិបាល
- ចំណូលស្របច្បាប់ផ្សេងៗទៀត ។

**ប្រការ ៩.-**

រាល់ការចំណាយថវិកាសហគមន៍ត្រូវអនុវត្តដូចតទៅ+

- ការចំណាយពី៣០.០០០រៀល ទៅ៥០.០០០រៀលត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ
- ការចំណាយពី ៣៣០.០០០រៀល ទៅ ៥០០.០០០រៀលត្រូវសម្រេចដោយគណៈកម្មការសហគមន៍នេសាទ
- ការចំណាយពី ៥០០.០០០រៀល ទៅ ១.០០០.០០០រៀល ត្រូវសម្រេចដោយមហាសន្និបាត

**ប្រការ ១០.-**

សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារនិងរៀបចំឱ្យមានបញ្ជី ÷

- ចំណូល ចំណាយថវិកា

- សារពើភ័ណ្ឌ
- សមាជិកសហគមន៍នេសាទ
- កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ
- កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ
- ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

**ប្រការ ១១.-**

ការគ្រប់គ្រង និងប្រើប្រាស់ថវិកា ÷

- ការគ្រប់គ្រងថវិកា ត្រូវមានការកាន់បញ្ជីគណនេយ្យ
- ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍នេសាទ
- រាល់ថវិកាចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីបត្រនិងចុះ បញ្ជីឱ្យបានត្រឹមត្រូវ
- ថវិកាដែលត្រូវចំណាយ គឺ សម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្សនិងអភិវឌ្ឍសហគមន៍នេសាទ ។

## ជំពូកទី ៥
## គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១២.-**

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាននិងសមាជិក ។ គណៈកម្មការសហគមន៍នេសាទត្រូវបោះឆ្នោតជ្រើសរើសសមាជិក ទទួលបន្ទុកលេខាធិការមួយរូបនិងសមាជិកទទួលបន្ទុកហិរញ្ញិកមួយរូប និងត្រូវពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង ។

ប្រធានគណៈកម្មការសហគមន៍នេសាទ ទទួលខុសត្រូវដឹកនាំនិងគ្រប់គ្រងសហគមន៍នេសាទទាំងមូល ។

អនុប្រធានគណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន ។

**ប្រការ ១៣.-**

គណៈកម្មការសហគមន៍នេសាទ មានអាណត្តិប្រាំ(៥)ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មី ដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតឱ្យចូលកាន់តំណែង ជំនួស ក្នុងករណីសហគមន៍នេសាទ ដំណើរការមិនប្រក្រតី ដោយមូលហេតុដំណើរការមិនល្អឬអសមត្ថភាពក្នុង ការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួនមួយភាគ បី(១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី ។

**ប្រការ ១៤.-**

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទ ណាម្នាក់អវត្តមានដោយគ្មានមូលហេតុរយៈពេល បី (៣) ខែឬសុំលាលែងមុនចប់អាណត្តិបេក្ខជន ដែលមានឈ្មោះតាមសំឡេងគាំទ្រ បន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាត កន្លងមកត្រូវបានជ្រើសតាំងជំនួស ។

## ជំពូកទី ៦
## របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១៥.-**

គណៈកម្មការសហគមន៍នេសាទ ត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ ។ កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ អាចប្រព្រឹត្តទៅបានលុះត្រាតែមានសមាជិកគណៈកម្មការ ចូលរួមយ៉ាងតិចចំនួន ២/៣ (ពីរភាគបី) នៃសមាជិករបស់គណៈកម្មការសហគមន៍នេសាទទាំងមូល ។

**ប្រការ ១៦.-**

ប្រធានគណៈកម្មការសហគមន៍នេសាទ ជាអ្នកកោះអញ្ជើញនិងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទ អវត្តមាន អនុប្រធាន ដែលបានការប្រគល់សិទ្ធិត្រូវធ្វើជា ប្រធានអង្គប្រជុំ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុនិងបញ្ជីវត្តមានច្បាស់លាស់។

ប្រធានអង្គប្រជុំ ត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទ ប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យ មានរបៀបរៀបរយនិងគ្មានការរំខាន ។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបានក្នុងករណីដែលសមាជិក នោះធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ ។

**ប្រការ ១៧.-**

ការសម្រេចលើបញ្ហាណាមួយ របស់សហគមន៍ ដូចមានចែងខាងក្រោមនេះគឺ ត្រូវអនុម័តដោយ កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាល នៃចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ ។ ក្នុងករណីដែលមានសម្លេងស្មើគ្នាមតិប្រធានអង្គប្រជុំជាឧត្តមានុភាព៖

- សេចក្តីព្រាងកិច្ចព្រមព្រៀងនិងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រាងគម្រោងថវិកា ចំណូលនិងចំណាយក្នុងសហគមន៍នេសាទ
- ការព្យួរសមាជិកភាព របស់សមាជិក ដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍នេសាទ ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានគណៈកម្មការសហគមន៍នេសាទ ត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិកសហគមន៍នេសាទអំពីសេចក្តីសម្រេចរបស់ខ្លួន ។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍នេសាទត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទឬសាលាឃុំ សង្កាត់ក្នុងរយៈពេល៧ថ្ងៃយ៉ាងយូរបន្ទាប់ពីការប្រជុំ។

## ជំពូកទី ៧
## មហាសន្និបាតសហគមន៍នេសាទ

**ប្រការ ១៨.-**

មហាសន្និបាតសហគមន៍នេសាទ ជាអង្គប្រជុំកំពូល ដើម្បីធ្វើការអនុម័តនិងធ្វើសេចក្តីសម្រេចចិត្តទាំងឡាយក្នុងនាមសហគមន៍នេសាទ ។ មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ត្រូវប្រារព្ធធ្វើឡើងបន្ទាប់ពី ក្រុមស្ថាបនិកបានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត ។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិកដែលបានដាក់ពាក្យស្នើសុំរួចមកហើយ ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ អនុម័តនូវសេចក្ដីសម្រេចនិងកិច្ចការសំខាន់ដូចខាងក្រោមៈ

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ ។

**ប្រការ ១៩**.-

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង ១ឆ្នាំម្ដង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍នេសាទ ។ ក្នុងករណីចាំបាច់សហគមន៍ អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំ ពីសមាជិកសហគមន៍នេសាទ ចំនួនមួយ ភាគបី (១/៣) យ៉ាងតិច ។

**ប្រការ ២០**.-

គណៈកម្មការសហគមន៍នេសាទ អាចអញ្ជើញ រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋានឬក្រុមប្រឹក្សាឃុំ សង្កាត់ សមត្ថកិច្ចពាក់ព័ន្ធនិងអ្នកគាំទ្រចូលរួមសង្កេតការណ៍ឬសម្របសម្រួលឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ

**ប្រការ ២១**.-

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម ៖

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្ដីជូនដំណឹងជាសាធារណៈនិងបិទប្រកាសនៅសាលាឃុំ សង្កាត់និងទីស្នាក់ការសហគមន៍នេសាទ
- ការកោះអញ្ជើញសមាជិកសហគមន៍នេសាទ ឱ្យចូលរួមមហាសន្និបាតសាមញ្ញត្រូវធ្វើឡើង ដប់(១០)ថ្ងៃ យ៉ាងតិច មុនថ្ងៃបើកមហាសន្និបាត និង បី (៣) ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ
- មហាសន្និបាតសាមញ្ញឬវិសាមញ្ញអាចប្រជុំពិភាក្សាអនុម័តនិងសម្រេចបានលុះត្រាតែមានវត្តមានលើសពីពាក់កណ្ដាល នៃចំនួនសមាជិកសហគមន៍នេសាទ
- អង្គប្រជុំមហាសន្និបាត ដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទឬប្រធានអង្គប្រជុំដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន
- មហាសន្និបាតត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្ដីសម្រេចនិងបញ្ជីវត្តមាន
- លេខាកត់ត្រា និង ប្រធានអង្គប្រជុំ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្ដីសម្រេចរបស់មហាសន្និបាតត្រូវយកសំឡេងលើសពីពាក់កណ្ដាលនៃចំនួនសមាជិកដែលមានវត្តមាន

**ប្រការ ២២**.-

មហាសន្និបាតអនុម័ត ៖

- សេចក្ដីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី ៣ លក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀងនិងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- តួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ

- ការសុំលាលែងឬការបណ្តេញចេញពីសមាជិកភាពឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ

## ជំពូកទី ៨
## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ២៣.-**

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទនិងចំនួនបេក្ខជនឈរឈ្មោះត្រូវអនុម័តដោយមហាសន្និបាត

**ប្រការ ២៤.-**

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ គឺជាភារកិច្ចរបស់គណៈកម្មការ រៀបចំការបោះឆ្នោត ដែលអនុម័តដោយមហាសន្និបាត ។ គណៈកម្មការរៀបចំការបោះឆ្នោត មានសមាសភាពពី បី(៣) ទៅ ប្រាំ(៥) នាក់ ដែលមានប្រធានអនុប្រធាននិងសមាជិក តាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាតនិងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានចំណេះដឹងនិងមានសីលធម៌ល្អ ។ គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់ ។

**ប្រការ ២៥.-**

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ចដូចខាងក្រោម ÷

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត
- បង្ហាញ រចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- រាប់សន្លឹកឆ្នោតនិងសរុបលទ្ធផលជូនគណៈអធិបតី ដើម្បីប្រកាសជូនមហាសន្និបាត
- ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផលបោះ-ឆ្នោតចប់ជាស្ថាពរ ។

**ប្រការ ២៦.-**

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ត្រូវទទួលតួនាទីជាអនុប្រធានជាសមាជិកគណៈកម្មការសហគមន៍នេសាទ តាមលំដាប់លំដោយ ។ ក្នុងករណីបេក្ខជនដែលមានសំឡេងគាំទ្រស្មើគ្នាត្រូវជ្រើសរើសស្ត្រីឬបោះឆ្នោតរកអ្នកដែលមានសមត្ថភាព ដោយលើកដៃយកមតិលើសពីពាក់កណ្តាល នៃចំនួនសមាជិកសហគមន៍នេសាទដែលចូលរួម ។

## ជំពូកទី ៩
## លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ និងនីតិវិធីដោះស្រាយវិវាទ

**ប្រការ ២៧**.-

ការរំសាយសហគមន៍នេសាទត្រូវផ្អែកតាម ៖

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀង-កន្លែងនេសាទសហគមន៍
- សេចក្តីសម្រេចមហាសន្និបាត ក្រោយពីរំសាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាតលើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ ។

**ប្រការ ២៨**.-

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ មានភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាង ឱ្យបានច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាមនៅមុនពេលប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យនិងសម្រេច ។

**ប្រការ ២៩**.-

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម ៖

- គណៈកម្មការសហគមន៍នេសាទ ត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទ ដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន
- ក្នុងករណីគណៈកម្មការសហគមន៍នេសាទ ដោះស្រាយវិវាទនោះ ពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផលដើម្បីដោះស្រាយទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់ ។
- ក្នុងករណីបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និង រដ្ឋបាលជល-ផលត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមី ដើម្បីដោះស្រាយតាមផ្លូវច្បាប់ ។

**ប្រការ ៣០**

សមាជិកសហគមន៍នេសាទរូបណា ដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវទទួលទណ្ឌកម្មពីគណៈកម្មការសហគមន៍នេសាទឬមហាសន្និបាតសហគមន៍នេសាទ ទៅតាមកម្រិត នៃទោសកំហុសរបស់ខ្លួន

## ជំពូកទី ១០
## នីតិវិធីនៃការកែប្រែលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

**ប្រការ ៣១**.-

ការកែប្រែលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ត្រូវសម្រេចដោយមហាសន្និបាត ។ ការលើកសំណើកែប្រែលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ត្រូវធ្វើឡើងដោយសមាជិកយ៉ាងតិច មួយភាគបី (១/៣) នៃសមា-

ជិកសហគមន៍នេសាទ  ទាំងអស់ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែមុនបើកមហាសន្និបាត ។ លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបានលុះត្រាតែមានសំឡេងយល់ព្រមលើសពីពាក់កណ្ដាលនៃសមាជិកមហាសន្និបាតសហគមន៍នេសាទ  ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**ប្រការ ៣២.**

លក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូង  នៅថ្ងៃទី២៧ ខែមេសា  ឆ្នាំ២០១២ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ

ភូមិតាម៉ៅ  ថ្ងៃទី..11......ខែមេសា ឆ្នាំ ២០១៣

**ប្រធានគណៈកម្មការសហគមន៍នេសាទរាធរ**

ម៉ម សុខុប

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : រាធរ |
| ភូមិ | : ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ |
| ឃុំ | : រាធរ |
| ស្រុក | : ព្រះស្ដេច |
| ខេត្ត | : ព្រៃវែង |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : រាធរ |
| ភូមិ | : ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ |
| ឃុំ | : រាធរ |
| ស្រុក | : ព្រះស្ដេច |
| ខេត្ត | : ព្រៃវែង |

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទ ឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយល្អ សហគមន៍នេសាទរាធរ សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម ៖

**ប្រការ ១.-**

គណៈកម្មការនិងសមាជិកសហគមន៍នេសាទគ្រប់រូបត្រូវមាន ការស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុងជួយស្តាបនា ព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចំរើនរបស់សហគមន៍នេសាទ ។

**ប្រការ ២.-**

គណៈកម្មការសមាជិកសហគមន៍នេសាទឬបុគ្គលណាដែលបានគេងប្រវ័ញ្ចធ្វើឱ្យខូចខាតឬបាត់បង់ទ្រព្យ សម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ ៖

- ចំពោះសមាជិកសហគមន៍នេសាទឬបុគ្គលដទៃទៀតត្រូវសងឬទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្តែង តាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ ។ ក្នុងករណីមិនព្រមសងត្រូវដាក់ជូនមហា-សន្និបាតសម្រេច
- ចំពោះគណៈកម្មការសហគមន៍នេសាទ ត្រូវសងឬទូទាត់សងការខូចខាតតាមការសម្រេចរបស់មហាសន្និបាត ប្រសិនបើនីតិវិធីខាងលើនេះនៅតែមិនអាចដោះស្រាយបានគឺត្រូវអនុវត្តតាមផ្លូវច្បាប់និងបទបញ្ញាជាធរមាន

**ប្រការ ៣.-**

សមាជិកសហគមន៍នេសាទគ្រប់រូបត្រូវតែចូលរួមមហាសន្និបាតនិងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទតាមការ កោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ ។ ក្នុងករណីដែលសមាជិកសហគបន៍ណាមិនបានមកចូលរួម ប្រជុំចំនួន ៣ដង ជាប់គ្នាដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ

ករណីនៅតែមិនរាងចាលគណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព ។

**ប្រការ ៤-**

សិទ្ធិដាក់ទណ្ឌកម្ម ៖

**ក- គណៈកម្មការសហគមន៍នេសាទ**

- អប់រំណែនាំលើកទី១ លើកទី២ លើកទី៣
- ព្រមានផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ
- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទនិងរាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផលចំពោះ ការនេសាទលើស ទំហំ ចំនួននិងខុសប្រភេទ ពេលវេលា ទីតាំង តាមការកំណត់នៅក្នុងផែនការគ្រប់គ្រងនិង កិច្ចព្រមព្រៀងនៅក្នុងកន្លែងនេសាទសហគមន៍ ។

**ខ- មហាសន្និបាត**

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ ៧ នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចលើសំណងការខូចខាតលើទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ

- ដាក់ទណ្ឌកម្មដល់សមាជិកឬបុគ្គលដទៃដែលគណៈកម្មការមិនអាចដោះស្រាយបាន ។

**ប្រការ ៥ .-**

សមាជិកសហគមន៍នេសាទគ្រប់រូបត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទអំពី សំភារៈ ឧបករណ៍នេសាទដែលគ្រួសារនីមួយៗ ប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ។

**ប្រការ ៦ .-**

សមាជិកសហគមន៍នេសាទប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ នៅក្នុងរដូវបើកនេសាទនិងរដូវបិទនេសាទដូចមានចែងខាងក្រោម ÷

- សន្ទូចបង្កៃ
- សន្ទូចរនង
- អង្រុត
- ទ្រូ
- កង្វា
- លបត្រី
- លបបង្កង
- លាន់អន្ទង់
- លបកំពិស
- មងរាយ
- ថ្នងដងអន្ទង់
- អួនអូសដោយដៃ (ប្រវែងមិនលើសពី ១០០ម )
- សំណាញ់

*សំគាល់:* សមាជិកសហគមន៍នេសាទ ប្រើប្រាស់ឧបករណ៍នេសាទយោងប្រកាសលេខ៤៥៨ ប្រក. កសក ការកែសម្រួលប្រកាសលេខ១២៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទគ្រួសារ ដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងដែននេសាទទឹកសាប នៃព្រះរាជាណាចក្រកម្ពុជា ។

ហាមឃាត់ដាច់ខាត ចំពោះការធ្វើនេសាទ គ្រប់ប្រភេទនៅក្នុងដែននេសាទឬកន្លែងនេសាទសហគមន៍ដោយប្រើប្រាស់ឧបករណ៍ដូចខាងក្រោមះ

ឧបករណ៍ឆក់ គ្រឿងផ្ទុះនិងសារធាតុពុលគ្រប់ប្រភេទ ។

ឧបករណ៍ បូម បាច ពង្រីង ផ្ទែកណាមួយ នៃដែននេសាទ ដែលបង្កមហន្តរាយដល់ធនធានជលផល ។

សម្រាស់ ឬ មធ្យោបាយផ្សេងទៀតដែលធ្វើឱ្យត្រី ឬ ភាវីសត្វកុំ ។

ច្បូក សាង ស្ទ ឬ ឧបករណ៍បាញ់ព្រួញដែលរួមផ្សំគ្រឿង ឆ្លុះ ។

មងបោះ មងកាំង ឬ មងពស់ថ្លាន់គ្រប់ប្រភេទ ។

មង ឬ អួនគ្រប់ ប្រភេទដែលមានក្រឡាតូចជាងមួយសង្ទីម៉ែត្រកន្លះ (១,៥ ស.ម) ក្នុងដែននេសាទទឹកសាប ឬកន្លែងនេសាទសហគមន៍ ។

មងគ្រប់ប្រភេទ ដែលមានក្រឡាធំជាង ដប់ប្រាំ(១៥)សង្ទីម៉ែត្រ ក្នុងដែននេសាទទឹកសាប ឬកន្លែងនេសាទ-សហគមន៍ ។

អួនអូសគូ ឬអួនហ៊ុមរួមផ្សំភ្លើងដែលធ្វើឱ្យត្រី ឬ ភាវីសត្វកុំ ។

ឧបករណ៍នេសាទស្បៃមុង គ្រប់ប្រភេទនៅទឹកសាប ។

អួនអូសគ្រប់ប្រភេទនៅទឹកសាប និងឈិបយន្ត ។

ព្រួលគ្រប់ប្រភេទ ដែលមានចន្លោះ ពីគ្រៀមមួយទៅគ្រៀមមួយ តូចជាងមួយសង្ទីម៉ែត្រកន្លះ (១,៥ស.ម) ។

ខ្សែចងគ្រប់ប្រភេទ និង មធ្យោបាយផ្សេងៗទៀត ដែលបង្កលក្ខណៈឱ្យត្រីធ្លើល ។

ទំនប់រួមផ្សំ ដោយឧបករណ៍នេសាទ គ្រប់ប្រភេទ ។

ឧបករណ៍នេសាទទំនើប ឬឧបករណ៍ដែលបង្កើតថ្មីឬរបៀបនេសាទបែបថ្មី ដែលនាំមកនូវការ បំផ្លាញមច្ឆជាតិ ធនធានជលផល ប្រព័ន្ធអេកូឡូស៊ីជលផលឬដែលគ្មានកំណត់ក្នុងប្រកាស របស់រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ។

ហាមឃាត់ការផលិត ការទិញ ការលក់ ការដឹកជញ្ជូន ការរក្សាទុក ឧបករណ៍ឆក់ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ អួនអូសគូ ឈិប យន្តនិងអួនអូសទឹកសាប ក្នុងបំណងធ្វើនេសាទ ។

ហាមឃាត់ ការចាក់ចោល ការបោះចោល ការបង្ហូរឬការបាចពង្រាយ ទៅក្នុងដែននេសាទនូវកាកសំណល់រឹងឬរាវឬសារធាតុពុល ដែលបានកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជានិងអនុសញ្ញាឬសន្ធិសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថាន ឬការប្រព្រឹត្តសកម្មភាពដែលធ្វើឱ្យពុល ឬ ការបង្កគ្រោះថ្នាក់ដល់វារីសត្វនិងវារីរុក្ខជាតិ ។

ហាមឃាត់ដាច់ខាត ការធ្វើនេសាទគ្រប់ប្រភេទគ្រប់ប្រភេទនៅអន្លង់អភិរក្សឬកន្លែងអភិរក្សត្រីមេពូជ

**ប្រការ ៧.-**

សមាជិកសហគមន៍នេសាទដែល ÷

- ប្រព្រឹត្តផ្ទុយឬរារាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិនិងកាតព្វកិច្ចដូចក្នុងប្រការ៥ នៃលក្ខន្តិកៈត្រូវ ព្យួរសមាជិក-ភាពដោយគណៈកម្មការសហគមន៍នេសាទឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាត
- មិនចូលរួម ថែរក្សាការពារធនធានជលផលឬមិនរាយការណ៍ពីសកម្មភាពបទល្មើសជលផល ត្រូវប្រមានដោយគណៈកម្មការសហគមន៍នេសាទ
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ កាប់ឆ្ការរានព្រៃលិចទឹកត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីជលផល
- ធ្វើនេសាទ ក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការ-នេសាទ និង រាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និង រដ្ឋបាលជលផលមានសមត្ថកិច្ច
- អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវផ្អាកការនេសាទ ទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទនិងរាយការណ៍ជាបន្ទាន់ជូនទៅរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីដោះស្រាយតាមច្បាប់ ។

**ប្រការ ៨.-**

ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទអាចមាន សិទ្ធិចេញចូល និងនេសាទ ក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយធ្វើកិច្ចសន្យានិងគោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងនិងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ព្រមទាំងបង់វិភាគទានចំនួន៧០.០០០រៀល ក្នុងមួយ១ខែសម្រាប់ការថែរក្សានិងការគ្រប់គ្រងធនធានជលផលនៅក្នុងសហគមន៍នេសាទ ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផល ដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបានគោរពតាមប្រការនេះ គណៈកម្មការសហគមន៍នេសាទ មានសិទ្ធិបញ្ឈប់សកម្មភាពនេសាទ របស់ជននោះ ហើយធ្វើការអប់រំណែនាំ

**ប្រការ ៩**.-

បទបញ្ញាផ្ទៃក្នុងសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទ លើកដំបូងនៅថ្ងៃទី២៧ ខែមេសាឆ្នាំ២០១២និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណៈកម្មការសហគមន៍នេសាទ

តាម៉ៅ ថ្ងៃទី..០៩.......ខែមេសា ឆ្នាំ ២០១៣

**ប្រធានគណៈកម្មការសហគមន៍នេសាទរាជធរ**

ង៉ម សុខុម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីថ្លែងការណ៍
# នៃការបង្កើតសហគមន៍នេសាទ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | : | រាធរ |
| ភូមិ | : | ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ |
| ឃុំ | : | រាធរ |
| ស្រុក | : | ព្រះស្តេច |
| ខេត្ត | : | ព្រៃវែង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីថ្លែងការណ៍
# នៃការបង្កើតសហគមន៍នេសាទ

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : រាធរ |
| ភូមិ | : ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ |
| ឃុំ | : រាធរ |
| ស្រុក | : ព្រះស្តេច |
| ខេត្ត | : ព្រៃវែង |

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីថ្លែងការណ៍
## នៃការបង្កើតសហគមន៍នេសាទរាធរ

សហគមន៍នេសាទរាធរ បានធ្វើមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ដែលមានអ្នកចូលរួមបោះឆ្នោតសរុប ៧២នាក់ ប្រុស៣១នាក់ ស្ត្រី៤២នាក់ និងបានរៀបចំរចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងសហគមន៍មានគណៈកម្មការចំនួន១១នាក់ ប្រុស១០ស្រី០១នាក់ និងក្រុមល្បាតចំនួន១២នាក់ ។

កន្លែងនេសាទសហគមន៍រាធរ មានទីតាំងស្ថិតនៅភូមិតាម៉ៅ ឃុំរាធរ ស្រុកព្រះស្តេច ខេត្តព្រៃវែង ។

កន្លែងនេសាទសហគមន៍រាធរ ត្រូវបានលុបចេញពីឡូត៍នេសាទលេខ១១ ជាដែននេសាទទឹកសាប ក្នុងខេត្តព្រៃវែង មានទំហំ ៦៦៩ហិកតា ។ និងមានព្រំប្រទល់៖

-ខាងជើងទល់នឹង ឃុំកំពង់សឹង

-ខាងត្បូងទល់នឹង ឃុំបឹងដោល

-ខាងកើតទល់នឹង ឃុំដៃកំពក

-ខាងលិចទល់នឹង ស្រុកពាមជរ

កន្លែងនេសាទសហគមន៍រាធរ មានកន្លែងអភិរក្សត្រីមេពូជ ចំនួន០១ កន្លែងអភិរក្សព្រៃលិចទឹកចំនួន ០១ ។

- បឹងទួលអ្នកតាស្នាយ ទំហំ ១.៣៤០ម៉ែត្រការ៉េ

- ព្រៃលិចទឹកទួលអ្នកតាស្នាយ ទំហំ ១.០៨០ ម៉ែត្រការ៉េ ។

កន្លែងនេសាទសហគមន៍រាធរ មានធនធានជលផលជាច្រើនដូចជា៖ ត្រីរ៉ស់ ត្រីព្រួល ត្រីប្រា ត្រីឆ្តោរ ត្រីឆ្លាំងត្រីកែស ត្រីឆ្តោក ត្រីក្អែក ត្រីទ្រនេល ត្រីគ្រសក់ ត្រីគល់រាំង ត្រីខ្វារ ត្រីខ្លា ត្រីកញ្ចុះ ត្រីលិញ ត្រីក្រាញ់ ត្រីចង្វារ ត្រីថ្កោងត្រីស្លូញ ត្រីពោ ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីកន្ទ្រប់ ក្លាំងហាយ ត្រីខ្នាន់ ត្រីកន្ធរ ត្រីក្រឡង់ ត្រីសណ្តាយ ត្រីអណ្តែងត្រីដំរី ត្រីតាអោន ត្រីក្រម៉ម ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ពឹង ត្រីកញ្ជួនដៃ ត្រីរមាស ត្រីគ្រុំ ត្រីផ្កាស្មៅ ត្រីឈ្វៀត ត្រីកញ្ជ្រូកត្រីបណ្តូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រការក្តាម ត្រីលលកសរ ត្រីឆ្ពិន ត្រីជញ្ជ្រក់ត្រីបណ្តូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ជ្រាញ់ច្រាស ប្រភេទវារីសត្វ ៖ អណ្តើក ពស់ ខ្យងគូចស្រួចខ្យងគូចទាល ខ្យងមាស (ខ្យងពណ៌លឿង) ក្តាម អន្ទង់ ខ្ញៅគូចស្រួច ខ្ញៅគូចទាល កង្កែប កន្ធាយ ឈ្លើង គ្រុំ លៀស និងប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ៖ដើមថ្លើមអណ្តើក ខ្លបយក្ស (អូយយ៉ាស់/បន្លាយយួន) រាំង ប្របួយមេប្របួយឈ្មោល ស្បាត ភ្នំភ្លែង អញ្ចាញ ត្តួ កន្សែង ស្នែងក្របី កន្សៀវ ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្នាង ត្តួ ខ្នាយមាន់វល្លិ៍ប្រេង វល្លិ៍ទឹកដោះ វល្លិ៍ត្រដិត វល្លិ៍ដោះគន់ វល្លិ៍ត្រី វល្លិ៍ត្អើក ល្ពាក់ទឹក ស្លាបទា កន្ទាំងហែ រញ្ជា ស្នោ ស្លត់ បន្លាឃ្លេផ្តោល ថ្នាន់ ស្នួលទឹក ច្រកែង ប្រផេញ ផ្តៅ ភ្នែកក្រាប បាក់ដង ត្រដក់ កន្ទុយអន្ទង់ ពោះក្អម វល្លិ៍អណ្តាតត្រកួត ក្រចាប់សារាយសាប កំប្លោក ចកតូច ចកធំ កំពឹងពួយស កំពឹងពួយក្រហម ត្រកួន ព្រលិតអាចមន៍មាន់ ព្រលិតដូង រំចង់ស្តន់អំបោះ ត្រាវអណ្តែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំបូង កក់ជ្រុង កក់ក្តាម ឈូក ចន្ទល់ភ្នំ (វល្លិ៍ថ្កាល់ត្រី) កញ្ឆែតស្មៅថ្នក់ទឹក ស្តន់ដំរី ។ល។

មុនការធ្វើមហាសន្និបាតកំណើតដំបូងធនធានទាំងនេះ មាននិន្នាការថយចុះជាលំដាប់ ដោយមិនមានការចូលរួមគ្រប់គ្រង ការពារ និងអភិរក្សធនធាន និងមានការប្រគួតប្រជែងគ្នាក្នុងការប្រើប្រាស់ធនធានជលផល ។

ដើម្បីដោះស្រាយបញ្ហានេះសម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសកែទម្រង់ស៊ីជម្រៅលើកទីពីរ បង្កើតជាសហគមន៍នេសាទក្នុងគោលបំណង៖

- ឱ្យប្រជាពលរដ្ឋរស់នៅក្នុងស្រុកព្រះស្តេច ចូលរួមគ្រប់គ្រង ការពារ អភិរក្ស និងប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនសមាជិកសហគមន៍នេសាទប្រកបដោយសមធម៌។
- ឱ្យប្រជាពលរដ្ឋក្នុងតំបន់បានដឹង និងទទួលស្គាល់កាន់តែច្បាស់នូវផលប្រយោជន៍ និងសារៈសំខាន់ធនធានជលផលព្រមទាំងមានគំនិតចូលរួមគ្រប់គ្រង និងការពារធនធានជលផលក្នុងសហគមន៍នេសាទ ដោយផ្ទាល់
- លើកស្ទួយកម្រិតជីវភាពរបស់ប្រជាពលរដ្ឋតាមមូលដ្ឋាន ។

យើងខ្ញុំសូមជម្រាបជូនលោកនាយខណ្ឌរដ្ឋបាលជលផលព្រៃវែង មេត្តាជ្រាបថា គណៈកម្មការ និងសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ខណ្ឌរដ្ឋបាលជលផលព្រៃវែង អង្គការចិត្តធម៌ និងរដ្ឋបាលជលផលថ្នាក់កណ្តាលបានសហការគ្នាចូលរួមប្រជុំពិគ្រោះយោបល់រៀបចំ៖

- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- បញ្ជីឈ្មោះ គណៈកម្មការ និងសមាជិកសហគមន៍នេសាទ
- របាយការណ៍បោះឆ្នោតជ្រើសរើសគណៈកម្មការ សហគមន៍នេសាទ
- រចនាសម្ព័ន្ធគណៈសហគមន៍នេសាទ
- ផែនទីកន្លែងនេសាទសហគមន៍ និងកន្លែងអភិរក្សត្រីមេពូជ មាត្រដ្ឋាន១/៥០.០០០
- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីថ្លែងការនៃការបង្កើតសហគមន៍នេសាទនិងការគ្រប់គ្រងធនធានជលផលដោយមានការធានាអះអាងអំពីការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព ។

ចាប់តាំងពីបង្កើតសហគមន៍នេសាទក្នុងឆ្នាំ២០១២ រហូតមកដល់សព្វថ្ងៃ គណៈកម្មការនិងសហគមន៍នេសាទបានព្យាយាមធ្វើការងារសំខាន់ៗ ដូចតទៅ៖

- បានបង្កើតកន្លែងអភិរក្សត្រីមេពូជ
- បានចូលរួមសហការ យាមល្បាតនៅកន្លែងនេសាទសហគមន៍ និងកន្លែងអភិរក្សត្រីមេពូជ
- បទល្មើសនេសាទមានការថយចុះជាលំដាប់
- បរិមាណផលត្រីក្នុងសហគមន៍នេសាទមានការកើនឡើងជាលំដាប់

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកនាយខណ្ឌរដ្ឋបាលជលផលព្រៃវែង មេត្តាពិនិត្យ និងសម្រេចចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រាធរ ដើម្បីឱ្យសហគមន៍យើងខ្ញុំបានទទួលស្គាល់តាមផ្លូវច្បាប់ ដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ។

សូមលោកនាយខណ្ឌរដ្ឋបាលជលផលព្រៃវែង មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

ភូមិតាម៉ៅ ថ្ងៃទី០៩..ខែ០៩.. ឆ្នាំ ២០១៣

**ប្រធានគណៈកម្មការសហគមន៍នេសាទរាធរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារផ្សេងៗ

ឈ្មោះសហគមន៍នេសាទ : រាធរ
ភូមិ : ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ
ឃុំ : រាធរ
ស្រុក : ព្រះស្ដេច
ខេត្ត : ព្រៃវែង

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារផ្សេងៗ

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : រាធរ |
| ភូមិ | : ឈ្នះជ័យលើ ឈ្នះជ័យក្រោម និងតាម៉ៅ |
| ឃុំ | : រាធរ |
| ស្រុក | : ព្រះស្ដេច |
| ខេត្ត | : ព្រៃវែង |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ប្រធានគណៈកម្មការសហគមន៍នេសាទរាជរ
## សូមគោរពជូន
## លោកនាយខណ្ឌរដ្ឋបាលជលផលព្រៃវែង

**កម្មវត្ថុ:** សំណើសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រាជរ ។

**យោង:** អនុក្រឹត្យ លេខ២៥ អនក្រ. បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
មហាសន្និបាតកំណើតដំបូងសហគមន៍នេសាទធ្វើនៅ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ។

**លិខិតភ្ជាប់:** កម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រាជរ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទសូមជម្រាបជូនលោកនាយខណ្ឌរដ្ឋបាលជលផលព្រៃវែង មេត្តាជ្រាបថា សហគមន៍នេសាទរាជរ បានបង្កើតឡើងដោយស្ម័គ្រចិត្ត និងមានគំនិតផ្តួចផ្តើមបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងស្រុកព្រះស្តេច។បន្ទាប់ពីធ្វើមហាសន្និបាតកំណើតដំបូងរួចមក គណៈកម្មការនិងសមាជិកសហគមន៍នេសាទ បានចូលរួមអនុវត្តយ៉ាងសកម្មជាមួយ ខណ្ឌរដ្ឋបាលជលផលព្រៃវែង រដ្ឋបាលជលផលថ្នាក់កណ្តាល អាជ្ញាធរដែនដី និង អង្គការចិត្តធម៌ ។

លទ្ធផលគួរកត់សំគាល់ដូចជា៖

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- ធ្វើបញ្ជីឈ្មោះ គណៈកម្មការ និងសមាជិកសហគមន៍នេសាទ
- ធ្វើរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ
- ធ្វើផែនទីកន្លែងនេសាទសហគមន៍ និងកន្លែងអភិរក្សត្រីមេពូជ មាត្រដ្ឋាន១/៥០.០០០
- ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- បានសហការយាមល្បាតកន្លែងនេសាទសហគមន៍និងកន្លែងអភិរក្សត្រីមេពូជ
- បានចូលរួមបង្ក្រាបបទល្មើសនេសាទ

យោងតាមសកម្មភាព និងលទ្ធផលទទួលបានប្រធានគណៈកម្មការសហគមន៍នេសាទរាជរសូមស្នើចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រាជរ ជាមួយលោកនាយខណ្ឌរដ្ឋបាលជលផលព្រៃវែង ។

អាស្រ័យហេតុនេះ សូមលោកនាយខណ្ឌរដ្ឋបាលជលផលព្រៃវែង មេត្តាពិនិត្យលើលទ្ធភាព និងរៀបចំកម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រាជរ តាមការស្នើសុំខាងលើ ព្រមទាំងផ្តល់ការគាំទ្រ ដល់សហគមន៍នេសាទរបស់យើងខ្ញុំដើម្បីគ្រប់គ្រងធនធានជលផល និងប្រើប្រាស់ធនធានជលផលក្នុងកន្លែងនេសាទសហគមន៍ទទួលបានជោគជ័យសម្រាប់កូនចៅជំនាន់ក្រោយ។

សូមលោកនាយខណ្ឌរដ្ឋបាលជលផលព្រៃវែង មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ភូមិតាម៉ៅ ថ្ងៃទី...០៧...ខែ...០៩... ឆ្នាំ ២០១៣

**ប្រធានគណៈកម្មការសហគមន៍នេសាទរាជរ**

ឃឹម សុខុម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ០០៣ /ប្រ.ក កសក

# ប្រកាស

## ស្តីពី

## ការចុះបញ្ជីសហគមន៍នេសាទចំនួន១៧ នៅខេត្តក្រចេះ ខេត្តកំពង់ចាម និងខេត្តព្រៃវែង

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ ... ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញប្រកាសលេខ៦៨១ ប្រក.កសក.ប ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងមន្ទីរពិសោធន៍ចំណុះនាយកដ្ឋាននិងវិទ្យាស្ថានក្រោមឱវាទរដ្ឋបាលជលផល
- បានឃើញប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

## សម្រេច

**ប្រការ ១._**

ត្រូវបានចុះបញ្ជីជាផ្លូវការនិងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនូវសហគមន៍នេសាទចំនួន១៧ រួមមាន៖ ខេត្តក្រចេះចំនួន០៤សហគមន៍នេសាទ ខេត្តកំពង់ចាមចំនួន០២សហគមន៍នេសាទ និងខេត្តព្រៃវែងចំនួន១១សហគមន៍នេសាទ ដែលមានឈ្មោះសហគមន៍នេសាទ ចំនួនសមាជិក ចំនួនគណៈកម្មការ ទំហំកន្លែងនេសាទសហគមន៍ ឈ្មោះ ភូមិ ឃុំ ស្រុក ខេត្ត និងនិយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ដូចមាននៅក្នុងតារាងនិងផែនទីកន្លែងនេសាទសហគមន៍នីមួយៗជាឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ។

**ប្រការ ២._**

ព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗដែលបានកំណត់ក្នុងផែនទី ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវបានទទួលស្គាល់ដោយនាយខណ្ឌរដ្ឋបាលជលផល អាជ្ញាធរដែនដី ប្រធានរដ្ឋបាលជលផល និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៣._**

ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ចំនួនភូមិ និងទីតាំងភូមិសាស្ត្ររបស់សហគមន៍ដូចមានចែងក្នុងប្រការ១ អាចកែប្រែបានតាមការចាំបាច់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៤._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥._**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឳវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្មខេត្តពាក់ព័ន្ធ និងប្រធានគណៈកម្មការសហគមន៍នេសាទត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ:** ភ្ជាប់ប្រកាសលេខ........០០៣ កសក..........ចុះថ្ងៃទី..០៦.......ខែ...ឧសភា........ឆ្នាំ២០១៦

## សហគមន៍នេសាទក្នុងខេត្តក្រចេះ ខេត្តកំពង់ចាម និងខេត្តព្រៃវែង

| ល.រ | ឈ្មោះសហគមន៍នេសាទ | ចំនួនសមាជិក (នាក់) | ចំនួនសមាជិកគណៈកម្មការសហគមន៍ | ទំហំផ្ទៃសហគមន៍ (ហិកតា) | ភូមិ | ឃុំ/សង្កាត់ | ស្រុក/ក្រុង | Projection :UTM, Everest 1830, Datum : Indian 1960, Zone : 48 N, Unit: Meter (X,Y) | (X,Y) |
|---|---|---|---|---|---|---|---|---|---|
| ១. ខេត្តក្រចេះ | | | | | | | | | |
| ០១ | វាលខ្សុង | ១០២ | ៩ | ៦៨៩,០៨ | សំភិន | កំពង់ចាម | សំបូរ | A- 604071, 1414129<br>B- 604310, 1414196<br>C- 604457, 1412059<br>D- 603739, 1411673 | E- 602165, 1413284<br>F- 602027, 1417649<br>G- 603003, 1417812 |
| ០២ | កាំងយាយម៉ៅ | ១១៣ | ៩ | ៦៧១,៧៩ | យាវ | កំពង់ចាម | សំបូរ | A- 603739, 1411673<br>B- 603392, 1409954<br>C- 602165, 1413284 | D- 600515, 1418928<br>E- 601656, 1418595 |
| ០៣ | ខ្សាច់ស្វាយប្រិមប្រិយ | ៩៨ | ៩ | ២៤៥,៩៤ | ទន្លេងធ្លាក់ | កំពង់ចាម | សំបូរ | A- 600515, 1418938<br>B- 601089, 1411210<br>C- 602165, 1413284 | D- 602513, 1422825<br>E- 601656, 1418598 |
| ០៤ | ក្រហមគោលបាក់ | ១៣១ | ៩ | ៤៨៥,៧៩ | អាជេន | កំពង់ចាម | សំបូរ | A- 601985, 1423093<br>B- 603646, 1425850<br>C- 605014, 1427480<br>D- 605884, 1428849 | E- 606308, 1428425<br>F- 605437, 1427247<br>G- 602513, 1412825 |

| ២. ខេត្តកំពង់ចាម | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ០១ | បឹងបេ០៦ | ១.៣៤២ | ១១ | ៩.៧៨៧,៥0 | -ព្រែកកុយ<br>-អន្លង់គគីរ<br>-អូរស្វាយលិច<br>-អូរស្វាយកើត<br>-ខ្ទបលើ<br>-ល្វាក្រោម<br>-អន្លង់គគីរ<br>-ស្តៅ<br>-កងតាណឹងទី១<br>-កងតាណឹងទី២<br>-កងតាណឹងទី៣<br>-កងតាណឹងទី៤<br>-កងតាណឹងទី៥<br>-កងតាណឹងទី៦<br>-កងតាណឹងទី៧<br>-កងតាណឹងទី៨<br>-កងតាណឹងទី៩<br>-ព្រែកលីវទី១<br>-ព្រែកលីវទី២<br>-ព្រែកលីវទី៣<br>-ព្រែកលីវទី៤<br>-ជ្រោយក្រពៅទី១ | -ព្រែកកុយ<br><br><br><br>-ស្តៅ<br><br><br><br>-កងតាណឹង<br><br><br><br><br><br><br><br><br>-រការអារ | កងមាស | A- 500630, 1311383<br>B- 500061, 1312624<br>C- 500525, 1315089<br>D- 500642, 1316362<br>E- 502069, 1317165<br>F- 503744, 1316244<br>G- 511002, 1319722<br>H- 515092, 1320787<br>I- 516399, 1312060<br>J - 517252, 1320022<br>K- 516045, 1319115<br>L- 514907, 1318556 | M- 514062, 1317762<br>N- 514031, 1317762<br>O- 513631, 1316347<br>P - 513954, 1315002<br>Q- 513900, 1312688<br>R- 513285, 1312664<br>S- 513308, 1312349<br>T- 513570, 1312049<br>U- 515246, 1312872<br>V - 509941, 1310673<br>W-507919,1310174<br>X- 506143, 1310666<br>Y- 504560, 1311827 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | -ជ្រោយក្របៅទី២<br>-ស្វាយស្រណោះទី១<br>-ស្វាយស្រណោះទី២<br>-រកាអារ<br>-ខ្ចៅទី១<br>-ខ្ចៅទី២<br>-ខ្ចៅទី៣<br>-វាំវិន្ទទី១<br>-វាំវិន្ទទី២<br>-វាំវិន្ទទី៣<br>-ព្រែកប្រណាក<br>-គកក្របី<br>-រាយប៉ាយលើ | -ខ្ចៅ<br><br><br><br><br><br>-រាយប៉ាយ | | | |
| ០២ | រកាគយ | ៣៣១ | ១១ | ១.៩៥០ | -រកាគយ.ក<br>-រកាគយ.ខ<br>-ភូមិថ្មី.ក<br>-ភូមិថ្មី.ខ<br>-ពង្រ<br>-ស្វាយតាហែន<br>-ដំណាក់ល្អិត | រកាគយ | កងមាស | A- 537732, 1319491<br>B- 534904, 1319835<br>C- 530561, 1320809 | D- 534351, 1324091<br>E- 536639, 1323986<br>F- 537225, 1322077 |

## ៣. ខេត្តព្រៃវែង

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ០១ | ស៊ីធរកណ្ដាល | ២៨៥ | ១១ | ៦.១៥៣ | -ព្រែកសណ្ដែក<br>-ព្រែកញ្ញៅ<br>-ព្រែកចង្ក្រានលើ<br>-ព្រែកចង្ក្រានក្រោម<br>-បាប្រីយ៍<br>-ល្វេ<br>-អំបែងចេះ<br>-កោងទន្លេក្រោម<br>-កោងស្រែ<br>-ព្រំមុន្នី<br>-កោងទន្លេលើ<br>-រលាំង<br>-ព្រៃលាន<br>-ចារ<br>-អន្លង់សរ<br>-ព្រៃពោធិ៍<br>-កំភារ<br>-ញ្ញៅ<br>-តាគ្រាប<br>-កំព្រៅ<br>-ទួលស្រឹង<br>-បន្លិចស្វាយ<br>-ផាត់សណ្ដាង | -ព្រែកចង្ក្រាន<br>-ល្វេ<br>-រំលេច<br>-ញ្ញៅទីមួយ | ស៊ីធរ<br>កណ្ដាល | A-540651, 1302517<br>B-540741, 1302998<br>C-540373, 1307005<br>D-540496, 1307836<br>E-539994, 1308195<br>F-539997, 1308989<br>G-538920, 1309791<br>H-538486, 1309815<br>I- 538143, 1310112<br>J -537758, 1310012<br>K-537081, 1310581<br>L-537143, 1310800<br>M-536292, 1311367<br>N- 536108, 1311896<br>O- 535653, 1311280<br>P -534149, 1310715<br>Q-534150, 1310716<br>R- 532511, 1310616<br>S- 532030, 1310197 | T- 531414, 1310443<br>U -531967, 1309702<br>V -531575, 1309001<br>W-531108, 1309300<br>X- 531881, 1305070<br>Y- 538338, 1302776<br>Z- 541592, 1305519<br>a-542431, 1305030<br>b-542702, 1305308<br>c-542374, 1305931<br>d-542794, 1306352<br>e-543399, 1306228<br>f-543416, 1306437<br>g-542268, 1307524<br>h-542292, 1307768<br>I- 541935, 1307762<br>j- 541129, 1309136<br>k- 541380, 1306609<br>l- 541602, 1306206 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | -ទួលអង្គុញ | | | | |
| ០២ | កន្ទិលសែនជ័យ | ២៥០ | ១១ | ៣.៦៧១ | -ព្រៃកជ្រៃលើ<br>-ព្រៃកជ្រៃក្រោម<br>-បាក់ដោក<br>-អន្លង់ទ្រា<br>-ពោធិ៍រៀងត្បូង<br>-ពោធិ៍រៀងជើង<br>-យាយសល់<br>-វាលព្រៅ<br>-ថ្មី<br>-អង្គរយស<br>-តាម៉ោ<br>-តាមែង<br>-ប្រាំងទទឹង<br>-ព្រៃកផ្តាំ<br>-ព្រៃកអន្ទះ | -ព្រៃកជ្រៃ<br><br><br><br>-ពោធិ៍រៀង<br><br><br><br>-ព្រៃកអន្ទះ | -ពោធិ៍រៀង | A-529862, 1265590<br>B-530665, 1266456<br>C-530961, 1266510<br>D-527599, 1272122<br>E-527411, 1271901<br>F-526950, 1273051<br>G-526279, 1274995<br>H-526436, 1275004<br>I- 526710, 1274004<br>J -528537, 1274003<br>K-528752, 1277299 | L-527757, 1278617<br>M-525014, 1277736<br>N- 525186, 1275845<br>O- 524535, 1273030<br>P -525300, 1273027<br>Q-526532, 1269357<br>R- 526554, 1267043<br>S- 527391, 1266335<br>T- 528315, 1265762<br>U-528989, 1266478 |
| ០៣ | បាទងសាមគ្គីប្រាំពីរមករា | ៩៥ | ១១ | ៣.៦២៣ | -បារាយណ៍លិច<br>-ភូមិលេខ១<br>-ភូមិលេខ២<br>-ព្រៃកណ្តៀង<br>-ពន្លៃ<br>-ស្តៅ<br>-ពាមស៊ី<br>-អន្លង់ទ្រា | -បារាយណ៍<br>-កំពង់លាវ<br><br>-ព្រៃកណ្តៀង<br><br><br>-ព្រៃកជ្រៃ | -ព្រៃវែង<br><br><br>-ពាមរក៍<br><br><br>-ពោធិ៍រៀង | A-534945, 1261132<br>B-534934, 1262282<br>C-534278, 1263940<br>D-534847, 1264856<br>E-535271, 1269421<br>F-532908, 1269247<br>G-532652, 1268669<br>H-533401, 1268094<br>I- 532945, 1266942 | J -531167, 1266211<br>K-531724, 1265275<br>L- 531410, 1264933<br>M-531711, 1264236<br>N- 532269, 1263912<br>O- 532919, 1262559<br>P -532436, 1262057<br>Q-532921, 1260942 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ០៤ | គេជោមេកឹង | ១.៨២១ | ១១ | ៤.៣១៦ | -ខ្សាច់<br>-អំពៅព្រៃ<br>-ស្វាយជ្រំ<br>-ដីស្រួត<br>-ជ្រៃថ្មី<br>-កោះរកា | -កោះសំពៅ<br><br>-កោះរការ | -ពាមជរ | A-522046, 1205906<br>B-522123, 1206571<br>C-523003, 1206571<br>D-522978, 1212655<br>E-523242, 1213015 | F-526452, 1213015<br>G-529484, 1204753<br>H-529245, 1204259<br>I- 526576, 1203799<br>J -524118, 1204699 |
| ០៥ | គេជោពោធិ៍ថ្មី | ១៦៥ | ១១ | ១.៥៧៦ | -អំពៅព្រៃ<br>-ពោធិ៍ថ្មី<br>-ស្វាយអណ្ដូង | -កោះសំពៅ | -ពាមជរ | A-529371, 1205846<br>B-530987, 1206293<br>C-532983, 1205011<br>D-534964, 1205001<br>E-535536, 1202336 | F-535658, 1202253<br>G-535172, 1201438<br>H-531586, 1203385<br>I- 529409, 1204243 |
| ០៦ | គេជោបឹងពោង | ២៥៧ | ១១ | ៣.៤៧០ | -កោះចេក<br>-មានជ័យ<br>-កោះពាមរាំង<br>-ស្ពាន<br>-កំពង់ប្រាសាទ<br>-តាហ៊ុយ<br>-ទឹកវិល<br>-ខ្ពប<br>-សំបួរ<br>-ព្រែកជ្រៅ<br>-បង្កែក | -កោះចេក<br><br><br><br>-កំពង់ប្រា<br>សាទ<br><br>-ព្រែកសំបួរ<br><br><br>-ស្វាយភ្លោះ | -ពាមជរ | A-524115, 1213006<br>B-524787, 1222506<br>C-525804, 1226611<br>D-526985, 1226593 | E-527003, 1227810<br>F-528801, 1227764<br>G-526458, 1212988 |
| ០៧ | គេជោសង្គ្រោះ<br>សែនជ័យ | ១៤៥ | ១១ | ២.២២១ | -លេខ៣<br>-លេខ៦<br>-ជើងទឹក ក | -កំពង់លាវ<br><br>-ជើងទឹក | -ព្រៃវែង | A-532907, 1269214<br>B-532178, 1273589<br>C-531827, 1273589<br>D-530503, 1275480<br>E-531421, 1278801 | H-535229, 1282933<br>I- 537552, 1281043<br>J -534365, 1279503<br>K-532745, 1277289<br>L- 533906, 1271888 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | -ជើងទឹក ខ<br>-កំពង់អាទង់<br>-ស្វាយសុខោ<br>-កំពង់ក្រមួន<br>-ស្វាយកំពឹងពួយ<br>-ព្រៃកន្លោង<br>-ពពឹស<br>-ជ្រាវ | -ព្រៃកន្លោង | -ពោធិ៍រៀង | F-533609, 1279125<br>G-534176, 1281529 | M-533798, 1271321<br>N- 534716, 1269349 |
| ០៨ | សាមគ្គីបឹងក្រចាប់ | ៩២ | ១១ | ៧.៥០៨ | -តាកែវ<br>-សហករណ៍<br>-ខ្លី<br>-ដង្កៀបក្ដាម<br>-ចំណងទាក<br>-បឹងក្រទឹប<br>-ជាងដែក<br>-តាមាស<br>-ក្រូច<br>-ព្រៃម្លូង<br>-អង្គ<br>-អង្រ្គង<br>-ក្រាំងវែង<br>-ឧកញ៉ាសឹង<br>-ពញាកើត<br>-ថ្លឹង | -ពាមមន្ទារ<br>-ជាងដែក | -កំពង់ត្របែក | A-546682, 1211972<br>B-546356, 1211972<br>C-548890, 1217157<br>D-548981, 1221585<br>E-549138, 1221598<br>F-550261, 1220932 | G-551972, 1220801<br>H-555028, 1222642<br>I- 555955, 1222669<br>J -555067, 1216334<br>K-555890, 1211019<br>L- 555485, 1210353 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | -តាបុល<br>-រការផ្លូវទី១<br>-រការផ្លូវទី២ | -បន្ទាយចក្រី | -ព្រះស្តេច | | |
| ០៩ | រាធរ | ៧២ | ១១ | ៦៦៩ | -តាម៉ៅ<br>-ឈ្នះដៃលើ<br>-ឈ្នះដៃក្រោម | -រាធរ | -ព្រះស្តេច | A-537545, 1233438<br>B-537529, 1231002<br>C-534769, 1228303<br>D-534198, 1228210<br>E-533905, 1229367<br>F-534214, 1229675 | G-535093, 1229645<br>H-536115, 1230945<br>I- 536666, 1233546<br>J -534754, 1234255<br>K-534760, 1234543 |
| ១០ | ពាមមានជ័យ | ៥២ | ១១ | ១.៥៣៧ | -បឹងក្អែក<br>-បឹងផ្សោត<br>-បន្លេច<br>-ចំការវែង<br>-ថ្មី | -ពាមមាន ជ័យ | -ពាមរក៍ | A-532205, 1261849<br>B-532784, 1260961<br>C-533685, 1254088<br>D-531721, 1251949<br>E-530833, 1251532 | F-531735, 1252487<br>G-531882, 1253375<br>H-531936, 1255325<br>I- 529986, 1257061<br>J -529999, 1259818 |
| ១១ | ឧត្តមសែនជ័យ | ២២៦ | ១១ | ២.៧៥២ | -ជ្រៃឧត្តម<br>-ក្រាំងតាយ៉ង<br>-កំពង់ប្រាសាទ<br>-តាហ៊ែល ក<br>-តាហ៊ិល ខ<br>-ក្លែងគង់ | -ក្រាំងតាយ៉ង<br><br>-កំពង់ប្រាសាទ<br>-រាធរ<br><br>-បឹងដោល | -ពាមជរ<br><br><br>-ព្រះស្តេច | A-526597, 1221023<br>B-526974, 1224671<br>C-528748, 1226038<br>D-529387, 1225994<br>E-529154, 1221692 | F-529402, 1227173<br>G-533587, 1227695<br>H-533413, 1223465<br>I- 529125, 1222331 |

បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានអាជ្ញាធរមីនជាតិ ...

អេង ជាសាន